N.9
08-3-02

ក

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ១_ព្រះរាជក្រម


០៧-០២-២០០២ -ព្រះរាជក្រមនស/រកម/០២០២/០០៦ ច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ៥២១


### ២_ ព្រះរាជក្រឹត្យ


២៧-០២-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០២០២/០៥០ ស្តីពីការតែងតាំងលោក **ថុង អ៊ុយផាង** ជា **ឧកញ៉ា** ៥៤៩

២៧-០២-២០០២ ព្រះរាជក្រឹត្យ នស/រកត/០២០២/០៥១ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ញាតូបនីយកម្មដល់លោក **តាំង ចាវទុង** ( TANG CHAO TUNG) សញ្ជាតិដើមចិន ៥៥០

២៧-០២-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០២០២/០៥២ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ញាតូបនីយកម្មដល់អ្នកស្រី **ចាង មៅ** ( CHANG MIAO) សញ្ជាតិដើមចិន ៥៥១

២៨-០២-២០០២ ព្រះរាជក្រឹត្យ នស/រកត/០២០២/០៥៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការ កំណត់អាសនៈរដ្ឋសភាសំរាប់នីតិកាលទី៣ ៥៥២

០៥-០៣-២០០២ ព្រះរាជក្រឹត្យ នស/រកត/០៣០២/០៥៧ ស្តីពីការតែងតាំងលោក **ម៉ក់ ពីត្វ** ជា **ឧកញ៉ា** ៥៥៤


## II- រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ


| | | |
|---|---|---|
| ០៤-០៣-២០០២ | អនុក្រឹត្យលេខ ១៧ អនក្រ .បក ស្តីពីការផ្ទេរគណនេយ្យទានថវិកា | ៥៥៥ |
| ០១-០៣-២០០២ | អនុក្រឹត្យលេខ ១០៦ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៥៥៧ |
| ០៤-០៣-២០០២ | អនុក្រឹត្យលេខ ១០៧ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៥៥៨ |
| ០៤-០៣-២០០២ | អនុក្រឹត្យលេខ ១០៨ អនក្រ .តត ស្តីពីការជូនមេដាយការងារ | ៥៥៩ |
| ០៤-០៣-២០០២ | អនុក្រឹត្យលេខ ១០៩ អនក្រ .តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ៥៦០ |
| ០៤-០៣-២០០២ | អនុក្រឹត្យលេខ ១១០ អនក្រ .តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៥៦២ |

| | | |
|---|---|---|
| ០៥-៣-២០០២ | អនុក្រឹត្យលេខ ១១១អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៥៦៣ |
| ០៥-៣-២០០២ | អនុក្រឹត្យលេខ ១១២ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៥៦៤ |
| ០៧-៣-២០០២ | អនុក្រឹត្យលេខ ១១៣ អនក្រ .តត ស្តីពីការជូនមេដាយសុវត្ថារា | ៥៦៥ |
| ០៧-៣-២០០២ | អនុក្រឹត្យលេខ ១១៤ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៥៦៦ |
| ០៧-៣-២០០២ | អនុក្រឹត្យលេខ ១១៥ អនក្រ .តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៥៦៧ |
| ០៧-៣-២០០២ | អនុក្រឹត្យលេខ ១១៦ អនក្រ .តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៥៦៨ |


## ២_សេចក្តីសំរេច


| | | |
|---|---|---|
| ០៥-៣-២០០២ | -សេចក្តីសំរេចលេខ ១៥ សសរ ស្តីពីការផ្ទេរសិទ្ធិ | ៥៦៨ក |
| ០៥-៣-២០០២ | -សេចក្តីសំរេចលេខ ១៦ សសរ ស្តីពីការគណៈកម្មការទទួលបន្ទុករៀបចំសន្និសិទកំពូលពុទ្ធសាសនាពិភពលោកលើកទី៣ថ្ងៃទី ០៥-៩ ធ្នូ ឆ្នាំ ២០០២ នៅរាជធានីភ្នំពេញ | ៥៦៨ខ |
| ០៩-៣-២០០២ | -សេចក្តីសំរេចលេខ ១៧ សសរ ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល | ៥៦៩ |


## ៣_ សារាចរណែនាំ


| | | |
|---|---|---|
| ០៥-៣-២០០២ | សារាចរណែនាំ លេខ ០៣ សរណន ស្តីពីការរៀបចំបុណ្យចូលឆ្នាំថ្មី ឆ្នាំ មមីចត្វាស័ក ពស ២៥៤៦ គស ២០០២ | ៥៧០ |


# III- ការងារបណ្តាក្រសួង

## ១_ ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


| | | |
|---|---|---|
| ០៤-៣-២០០២ | ប្រកាសអន្តរក្រសួងលេខ ២២៣ សហវ ស្តីពីការបង្កើតរង្វាន់ទេយ្យបុរេប្រទាននៅក្រសួង សង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា | ៥៧៣ |
| ០៤-៣-២០០២ | ប្រកាសលេខ ២២៤សហវ ស្តីពីការបង្កើតផ្នែកគ្រប់គ្រងនិងប្រមូល ពន្ធតាមរបបពិត | ៥៧៥ |
| ០៥-៣-២០០២ | ប្រកាសអន្តរក្រសួងលេខ ២២៥ សហវ ស្តីពីការបង្កើតរង្វាន់ទេយ្យ បុរេប្រទាននៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ៥៧៧ |
| ០៦-៣-២០០២ | ប្រកាសអន្តរក្រសួងលេខ ២២៧ សហវ ស្តីពីការតែងតាំងភ្នាក់ងារ បើកផ្តល់សំរាប់បើកប្រាក់បៀវត្ស និងប្រាក់អន្តរាគមន៍ ក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌ជូនមន្ត្រីរាជការនៅអាជ្ញាធរសវនកម្មជាតិ | ៥៧៩ |

9

# គ

## ២_ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


០៧-៣-២០០២ ប្រកាសលេខ ០៨៣ Moc/M2002ស្ដីពីការរឹបអូសប្រាក់កក់ពីក្រុម ហ៊ុន ដែលមិនបានទទួលយកកូតាដេញថ្លៃសំរាប់នាំចេញទៅកាន់សហ រដ្ឋអាមេរិកដែលបានដាក់ឱ្យដេញថ្លៃកាលពីថ្ងៃទី ២៨ខែមករាឆ្នាំ២០០២ ៥៨១


## សេចក្ដីជូនដំណឹង


០៧-៣-២០០២ សេចក្ដីជូនដំណឹងលេខ ៧៧៣ Moc/M 2002 ស្ដីពីការផ្ដល់ប្រព័ន្ធ អនុគ្រោះពាណិជ្ជកម្ម MFN របស់ប្រទេសចិនដល់ព្រះរាជា ណាចក្រកម្ពុជា ៥៨៣


## ៣_ទីស្ដីការរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ


០៤-០៣-២០០២ ប្រកាសលេខ ៦៦ប្រក.កអជ ស្ដីពីការបង្កើតក្រុមការងារកសាងផែន ការឯក សារយុទ្ធសាស្ត្រសំរាប់កាត់បន្ថយភាពក្រីក្រ ៥៨៤

# ព្រះរាជក្រម

នស/រកម/០២០២/០០៦

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

# ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើក ទី ៦ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់

# ស្តីពី

# ម៉ាក ពាណិជ្ជនាម និងអំពើ
# នៃការប្រកួតប្រជែងមិនស្មោះត្រង់

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងការពារម៉ាក ពាណិជ្ជនាមដែលបានចុះបញ្ជីក្នុងបញ្ជីម៉ាក នៅក្នុងព្រះរាជាណាចក្រកម្ពុជានិងប្រឆាំងការប្រកួតប្រជែងមិនស្មោះត្រង់លើការបង្កើត ការប្រើប្រាស់ម៉ាក និងពាណិជ្ជនាម ។

**មាត្រា ២.-**

**ក-ម៉ាក** គឺជាសញ្ញាដែលមើលឃើញ ហើយអាចសំគាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសនីមួយៗ ។ ម៉ាកដែលប្រើប្រាស់សំរាប់ទំនិញហៅថាពាណិជ្ជសញ្ញា ហើយម៉ាកដែលប្រើប្រាស់សំរាប់សេវាហៅថា សេវាសញ្ញា ។

**ខ-ម៉ាកសមូហភាព** គឺជាសញ្ញាដែលមើលឃើញ សំដៅប្រើក្នុងការដាក់ពាក្យសុំចុះបញ្ជី ហើយអាចសំគាល់នូវប្រភពដើមនៃទំនិញឬសេវា ឬសំគាល់នូវចរិតលក្ខណៈរួមដទៃទៀត គិតទាំងគុណភាពនៃទំនិញឬសេវារបស់សហគ្រាសផ្សេងៗគ្នា ដែលប្រើសញ្ញានោះ ក្រោមការគ្រប់គ្រងរបស់ម្ចាស់ម៉ាកសមូហភាពដែលបានចុះបញ្ជី ។

**គ-ពាណិជ្ជនាម** គឺជាឈ្មោះ ឬសញ្ញាសំគាល់ ឬជាឈ្មោះនិងសញ្ញាសំគាល់សំរាប់បញ្ជាក់និងសំគាល់លក្ខណៈខុសៗគ្នានៃសហគ្រាសនីមួយៗ ។

**មាត្រា ៣.-**

សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវបានទទួលស្គាល់តាមរយៈការចុះបញ្ជី ដោយអនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ។

**មាត្រា ៤.-**

ម៉ាកដែលមិនអាចចុះបញ្ជីបានមានដូចតទៅ :

**ក-** ម៉ាកដែលមិនអាចសំគាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវារបស់សហគ្រាសមួយទៅនឹងសហគ្រាសមួយផ្សេងទៀត ។

ខ- ម៉ាកដែលបណ្ដាលឱ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ សីលធម៌ ឬប្រពៃណីល្អរបស់ជាតិ ។

គ- ម៉ាកដែលអាចនាំឱ្យសាធារណជន ឬមជ្ឈដ្ឋានពាណិជ្ជកម្មភាន់ច្រឡំទៅនឹងប្រភពភូមិសាស្ត្រនៃទំនិញ ឬសេវាពាក់ព័ន្ធ ឬធាតុដើម ឬលក្ខណៈខាងក្រៅរបស់ទំនិញ ឬសេវានោះ ។

ឃ- ម៉ាកដែលដូចគ្នានិង/ ឬត្រាប់តាម ឬមានចំណុចណាមួយដូចសញ្ញាជាតិ ទង់ជាតិនិងនិមិត្តរូបផ្សេងៗ ឈ្មោះ ឬឈ្មោះសង្ខេប ឬអក្សរកាត់នៃឈ្មោះ ឬសញ្ញា ឬត្រាជាផ្លូវការដែលអនុម័តដោយរដ្ឋណាមួយ អង្គការអន្តររដ្ឋាភិបាល ឬអង្គការដែលបង្កើតដោយអនុសញ្ញាអន្តរជាតិមួយ លើកលែងតែមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋនោះ ឬអង្គការនោះ ។

ង- ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែល ដែលនាំឱ្យច្រឡំគ្នានឹងម៉ាក ឬពាណិជ្ជនាមមួយដែលល្បីក្នុងព្រះរាជាណាចក្រកម្ពុជា ឬបង្កើតពីការបកប្រែនៃម៉ាក ឬពាណិជ្ជនាមដែលល្បីនោះសំរាប់ទំនិញ ឬសេវាដូចគ្នា ឬប្រហាក់ប្រហែលគ្នានៃសហគ្រាសមួយទៀត ។

ច- ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែលដែលនាំឱ្យច្រឡំគ្នានឹងម៉ាក ឬពាណិជ្ជនាមមួយដែលល្បី ឬបង្កើតពីការបកប្រែនៃម៉ាក ឬពាណិជ្ជនាមដែលល្បីនោះ ហើយដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ទំនិញ ឬសេវាដែលមិនដូចគ្នា ឬមិនប្រហាក់ប្រហែលគ្នាដោយការប្រើប្រាស់ម៉ាកនោះធ្វើឱ្យខូចប្រយោជន៍របស់ម្ចាស់នៃម៉ាកល្បី ។

ឆ- ម៉ាកដែលដូចគ្នា ឬស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងម៉ាក ដែលជាកម្មសិទ្ធិរបស់ម្ចាស់ផ្សេងដែលបានចុះបញ្ជីរួចហើយ ឬបានដាក់ពាក្យស្នើសុំចុះបញ្ជីមុន ឬបានទទួលអាទិភាពចុះបញ្ជីមុននៅឯបរទេស ចំពោះទំនិញឬសេវាដូចគ្នា ឬទំនិញឬសេវាដែលពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធ ។

# ជំពូកទី ២

## ការចុះបញ្ជីនិងសិទ្ធិដែលកើតឡើងពីការចុះបញ្ជីម៉ាក

**មាត្រា ៥.-**

បែបបទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ការសុំប្តូរអាស័យដ្ឋាននៃម្ចាស់ម៉ាកនិងការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាកត្រូវបានកំណត់ដូចខាងក្រោម :

ក- ការស្នើសុំចុះបញ្ជីម៉ាក ការសុំប្តូរអាស័យដ្ឋាននៃម្ចាស់ម៉ាកនិងការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ឬមិនបានប្រើប្រាស់ម៉ាក ត្រូវធ្វើនៅក្រសួងពាណិជ្ជកម្ម ។

ពាក្យស្នើសុំត្រូវភ្ជាប់ :

-គំរូម៉ាក

-បញ្ជីទំនិញឬសេវាដែលត្រូវចុះបញ្ជី ដោយរាយលំអិតតាមក្រុមមុខទំនិញទៅតាមចំណាត់ថ្នាក់អន្តរជាតិ ដូចមានក្នុងឧបសម្ព័ន្ធ ។

ខ- ការសុំចុះបញ្ជីម៉ាក ការសុំប្តូរអាស័យដ្ឋាននៃម្ចាស់ម៉ាកនិងការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ឬមិនបានប្រើប្រាស់ម៉ាក ត្រូវបង់កម្រៃតាមការកំណត់នៅក្នុងសេចក្តីប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៦.-**

សិទ្ធិអាទិភាពក្នុងការចុះបញ្ជីម៉ាក ត្រូវបានផ្តល់តាមល័ក្ខខ័ណ្ឌដូចខាងក្រោម :

ក- អ្នកស្នើសុំចុះបញ្ជីអាចស្នើសុំអាទិភាពនៃការចុះបញ្ជី ដោយអមមកជាមួយនូវប្រកាសស្តីពីអាទិភាពដែលខ្លួនមាន តាមរយៈការស្នើសុំចុះបញ្ជីនៅប្រទេសណាមួយដែលជាសមាជិកនៃអនុសញ្ញាក្រុងប៉ារីស ។

ខ- តម្លៃនៃប្រកាសស្តីពីអាទិភាពខាងលើ ត្រូវតែស្របទៅតាមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងអនុសញ្ញាទីក្រុងប៉ារីស ។

មាត្រា ៧.-

អ្នកស្នើសុំចុះបញ្ជីអាចដកពាក្យស្នើសុំរបស់ខ្លួននៅពេលណាក៏បាន ។

មាត្រា ៨.-

ក្រោយពេលទទួលពាក្យស្នើសុំចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជីត្រូវ :

ក- ពិនិត្យមើលពាក្យស្នើសុំនោះឱ្យបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌនៃមាត្រា ៥ និងបទបញ្ញាដែលជាប់ទាក់ទង ។

ខ- ពិនិត្យនិងកំណត់ថាម៉ាកនោះគឺជាម៉ាកស្របតាមល័ក្ខខ័ណ្ឌដូចមានចែងនៅក្នុងមាត្រា ២ ចំណុច ក និងមិនអាចចុះបញ្ជីបានតាមមាត្រា ៤ ដោយលើកលែងតែចំណុច ឆ នៃមាត្រា ៤ នេះចេញ ។

មាត្រា ៩.-

អាទិភាពនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវបានកំណត់ដូចតទៅ :

ក- កាលណាមានពាក្យស្នើសុំចុះបញ្ជីច្រើនទាក់ទងនឹងម៉ាកដែលដូចឬប្រហាក់ប្រហែលគ្នាដែលត្រូវបានប្រើចំពោះទំនិញ ឬសេវាដូច ឬប្រហាក់ប្រហែលគ្នា ហើយបានដាក់ពាក្យស្នើសុំតាមពេលវេលាខុសគ្នា មន្ត្រីកាន់កាប់បញ្ជីអាចបដិសេធការចុះបញ្ជីម៉ាកណាមួយនៃម៉ាកទាំងនោះរហូតដល់ពេលដែលសិទ្ធិនៃអ្នកស្នើសុំទាំងនោះត្រូវបានកំណត់ដោយមន្ត្រីកាន់កាប់បញ្ជី ឬត្រូវបានដោះស្រាយដោយការព្រមព្រៀងគ្នា និងមានការយល់ព្រមពីមន្ត្រីកាន់កាប់បញ្ជី ។

ខ- កាលណាមានពាក្យស្នើសុំចុះបញ្ជីច្រើនទាក់ទងនឹងម៉ាកដែលដូច ឬប្រហាក់ប្រហែលគ្នាដែលត្រូវបានប្រើចំពោះទំនិញ ឬសេវាដូច ឬប្រហាក់ប្រហែលគ្នា ហើយបានដាក់ពាក្យស្នើសុំក្នុងពេលជាមួយគ្នា ក្រោយពីការពិគ្រោះឯកភាពគ្នាទៅវិញទៅមកក្នុងចំណោមអ្នកស្នើសុំទាំងអស់ មានអ្នកស្នើសុំតែម្នាក់គត់ដែលអាចទទួលបាននូវការចុះបញ្ជីម៉ាក ។

មាត្រា ១០.-

សិទ្ធិរបស់មន្ត្រីកាន់កាប់បញ្ជី ក្នុងការចុះបញ្ជីម៉ាកមានដូចខាងក្រោម :

ក- ក្នុងករណីដែលមន្ត្រីកាន់កាប់បញ្ជីរកឃើញថាល័ក្ខខ័ណ្ឌទាំងឡាយដែលមានចែងក្នុងមាត្រា ៨ និងមាត្រា ៩ បានត្រូវបំពេញ មន្ត្រីកាន់កាប់បញ្ជីត្រូវចុះបញ្ជីម៉ាក ចេញវិញ្ញាបនប័ត្រនៃការចុះបញ្ជីជូនអ្នកស្នើសុំនិងចុះផ្សាយក្នុងព្រឹត្តិប័ត្រផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម ។

ខ- ពាក្យស្នើសុំចុះបញ្ជីដែលមិនបានសមស្របតាមមាត្រា ៨ អ្នកស្នើសុំចុះបញ្ជី អាចកែតម្រូវក្នុងរយៈពេល ៤៥ (សែសិបប្រាំ)ថ្ងៃ បន្ទាប់ពីថ្ងៃជូនដំណឹងជាលាយលក្ខណ៍អក្សររបស់មន្ត្រីកាន់កាប់បញ្ជី ។ ក្នុងករណីគ្មានការកែតម្រូវពាក្យស្នើសុំពីអ្នកសុំចុះបញ្ជីតាមកាលកំណត់ មន្ត្រីកាន់កាប់បញ្ជីមានសិទ្ធិបដិសេធការចុះបញ្ជីម៉ាកនោះ ។

គ- ក្នុងរង្វង់ ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីបានចុះផ្សាយក្នុងព្រឹត្តិប័ត្រផ្លូវការហើយ ជនណាដែលមានការពាក់ព័ន្ធ អាចជូនដំណឹងទៅមន្ត្រីកាន់កាប់បញ្ជីពីការជំទាស់របស់ខ្លួនចំពោះការចុះបញ្ជីម៉ាក តាមបែបបទដែលបានកំណត់ដោយឈរលើមូលដ្ឋាននៃការមិនបានបំពេញតាមល័ក្ខខ័ណ្ឌណាមួយនៃមាត្រា ២ ចំណុច ក មាត្រា ៤ និងមាត្រា ៥ និងបទបញ្ញាទាំងឡាយដែលពាក់ព័ន្ធ ។

ឃ- មន្ត្រីកាន់កាប់បញ្ជីត្រូវបញ្ជូនជាបន្ទាន់នូវសេចក្តីជូនដំណឹងនោះមួយច្បាប់ទៅអ្នកសុំចុះបញ្ជីតាមពេលវេលានិងបែបបទដែលបានកំណត់ ។ បន្ទាប់មកអ្នកស្នើសុំចុះបញ្ជីត្រូវបញ្ជូនទៅមន្ត្រីកាន់កាប់បញ្ជីនូវចម្លើយបញ្ជាក់អំពីមូលដ្ឋានបង្អែកទាំងឡាយសម្រាប់ការចុះបញ្ជីរបស់ខ្លួន ។ ប្រសិនបើមិនបានឆ្លើយតបទេ ម្ចាស់ម៉ាកនោះត្រូវចាត់ទុកថាបានបោះបង់ចោលការចុះបញ្ជីរបស់ខ្លួន ។

ង- ប្រសិនបើអ្នកសុំចុះបញ្ជីធ្វើពាក្យជំទាស់ មន្ត្រីកាន់កាប់បញ្ជីត្រូវផ្តល់ចម្លើយមួយច្បាប់ទៅអ្នកដែលបានប្តឹងជំទាស់ ។ ប្រសិនបើភាគីម្ខាង ឬភាគីទាំងសងខាងមានបំណងចង់ឱ្យមានសវនាការ មន្ត្រីកាន់កាប់បញ្ជីត្រូវរៀបចំឱ្យមានសវនាការនោះ ។ បន្ទាប់ពីបានស្តាប់ភាគីទាំងសងខាងនិងពិចារណាលើពាក្យតវ៉ា មន្ត្រីកាន់កាប់បញ្ជីត្រូវ

សម្រេចថាម៉ាកដែលបានចុះបញ្ជីនេះត្រូវរក្សាទុក ឬបដិសេធ ។

**មាត្រា ១១.-**

សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាកមានដូចខាងក្រោម :

ក- ចំពោះម៉ាកដែលទាក់ទងនឹងទំនិញ ឬសេវាដែលបានចុះបញ្ជីរួចហើយ ការប្រើប្រាស់ម៉ាកនោះដោយជនណាមួយក្រៅពីម្ចាស់ដើម ត្រូវមានការយល់ព្រមពីម្ចាស់ដើមជាមុនសិន ។

ខ- ម្ចាស់ដើមនៃម៉ាកមានសិទ្ធិប្ដឹងទៅតុលាការប្រឆាំងនឹងជនណាម្នាក់ដែលប្រើប្រាស់ដោយរំលោភនូវម៉ាករបស់ខ្លួន ដោយគ្មានការយល់ព្រមពីម្ចាស់ដើម ។ ម្ចាស់ដើមក៏មានសិទ្ធិប្ដឹងផងដែរ ចំពោះការប្រើប្រាស់នូវសញ្ញាដែលប្រហាក់ប្រហែលនឹងម៉ាក ដែលខ្លួនបានចុះបញ្ជីរួចហើយនិងការប្រើប្រាស់ម៉ាកដែលទាក់ទិនទៅនឹងទំនិញនិងសេវាដែលប្រហាក់ប្រហែលទៅនឹងទំនិញ ឬសេវានៃម៉ាកដែលចុះបញ្ជីរួចហើយនោះហើយដែលអាចបណ្ដាលឱ្យមានការភាន់ច្រឡំជាសាធារណៈ ។

គ- សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាកនឹងមិនរាប់បញ្ចូលនូវការដាក់លក់ទំនិញនៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់ដែលបានចុះបញ្ជី ឬដោយមានការយល់ព្រមពីម្ចាស់ម៉ាកនោះទេ ។

**មាត្រា ១២.-**

សុពលភាពក្នុងការចុះបញ្ជីម៉ាកនិងការចុះបញ្ជីសាជាថ្មីត្រូវបានកំណត់តាមល័ក្ខខ័ណ្ឌដូចខាងក្រោម :

ក- ម៉ាកដែលបានចុះបញ្ជីហើយ មានសុពលភាព ១០(ដប់) ឆ្នាំចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំចុះបញ្ជី ។

ខ- តាមការស្នើសុំ ការចុះបញ្ជីម៉ាកមួយ អាចធ្វើឡើងសាជាថ្មីសំរាប់រយៈពេល ១០ (ដប់)ឆ្នាំ ម្ដងជាបន្តបន្ទាប់ក្នុងល័ក្ខខ័ណ្ឌដែលម្ចាស់ដើមបង់អាករចុះបញ្ជីជាថ្មីតាមការកំណត់ ។

គ- ក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីសាជាថ្មីនូវម៉ាកដែលបានចុះបញ្ជីរួចហើយ មុនពេលដែលច្បាប់នេះចូលជាធរមាន អ្នកស្នើសុំត្រូវបញ្ជាក់ឱ្យបានច្បាស់នូវប្រភេទទំនិញ ឬសេវាដែលចង់បានការការពារ ដោយផ្អែកតាមចំណាត់ថ្នាក់អន្តរជាតិ ។

ឃ- ការអនុគ្រោះចំពោះការយឺតយ៉ាវក្នុងការចុះបញ្ជីសាជាថ្មីត្រូវបានអនុញ្ញាតត្រឹមតែរយៈពេល ៦ (ប្រាំមួយ) ខែ ។

## ជំពូកទី ៣
## មោឃភាពនិងការលុបម៉ាកចេញពីបញ្ជី

**មាត្រា ១៣.-**

មោឃភាពនិងអានុភាពនៃមោឃភាពត្រូវបានកំណត់ដូចខាងក្រោម :

ក- ជនណាដែលមានការពាក់ព័ន្ធ អាចស្នើសុំមកក្រសួងពាណិជ្ជកម្មឱ្យផ្តល់មោឃភាពដល់ការចុះបញ្ជីម៉ាកបាន ។

ខ- ក្រសួងពាណិជ្ជកម្មត្រូវទុកការចុះបញ្ជីជាមោឃៈ ប្រសិនបើជនដែលស្នើសុំឱ្យមានមោឃភាពនោះ បង្ហាញថាមានល័ក្ខខ័ណ្ឌណាមួយនៃមាត្រា ២ ចំណុច **ក** និងមាត្រា ៤ មិនត្រូវបានបំពេញ ។

គ- មោឃភាពនៃការចុះបញ្ជីម៉ាកត្រូវមានអានុភាពចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជី ហើយត្រូវបានកត់ត្រានិងបោះពុម្ពផ្សាយជាបន្ទាន់ ។

**មាត្រា ១៤.-**

ក្រសួងពាណិជ្ជកម្មមានសិទ្ធិលុបចោលម៉ាកដែលបានចុះបញ្ជីរួចហើយក្នុងករណីដូចខាងក្រោម :

ក- អ្នកសុំចុះបញ្ជីមិនបានដាក់ពាក្យស្នើសុំចុះបញ្ជីសាជាថ្មីនូវម៉ាកដែលបានចុះបញ្ជីរួចហើយតាមរយៈពេលដែលបានកំណត់ក្នុងមាត្រា ១២ ចំណុច **ខ** និងចំណុច **ឃ** ។

ខ- ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយ ស្នើសុំលុប ។

គ- ក្នុងរយៈពេល ៩០ (កៅសិប)ថ្ងៃ ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច ហើយមិនគោរពល័ក្ខខ័ណ្ឌនៃការផ្តល់ឯកសារគាំទ្រ ឬការកម្រិតដែលបានកំណត់នៅក្នុង មាត្រា ៨ ។

ឃ- ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយលែងមានអាស័យដ្ឋានទាក់ទងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ង- ជឿជាក់ដោយផ្អែកលើភ័ស្តុតាងថា ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច ហើយមិនមែនជាម្ចាស់ស្របច្បាប់ ។

ច- ជឿជាក់ថាម៉ាកដែលបានចុះបញ្ជីរួច ហើយប្រហាក់ប្រហែលឬដូចគ្នាទៅនឹងម៉ាកល្បីដែលជាកម្មសិទ្ធិរបស់ភាគីទីបី ។

**មាត្រា ១៥.-**

ម៉ាកដែលបានចុះបញ្ជីរួច ប៉ុន្តែមិនបានប្រើប្រាស់សោះក្នុងរយៈពេល ៥(ប្រាំ) ឆ្នាំ ត្រូវបានលុបចេញពីបញ្ជី ។ ប្រសិនបើម្ចាស់ម៉ាកបង្ហាញថា កាលៈទេសៈពិសេសបានរារាំងការប្រើប្រាស់ម៉ាក ហើយគ្មានបំណងមិនប្រើ ឬបោះបង់ចោលម៉ាកនោះទេ ម៉ាកនោះ នឹងមិនត្រូវបានលុបចេញពីបញ្ជីឡើយ ។ ជនណាដែលពាក់ព័ន្ធអាចស្នើសុំឱ្យក្រសួងពាណិជ្ជកម្មលុបម៉ាកចេញពីបញ្ជី ១ (មួយ) ខែ មុនកាលបរិច្ឆេទ ៥(ប្រាំ) ឆ្នាំ នៃការមិនបានប្រើប្រាស់ ឬក្រោយកាលបរិច្ឆេទនេះ ។

## ជំពូកទី ៤
## ម៉ាកសមូហភាព

**មាត្រា ១៦.-**

បទប្បញ្ញត្តិទាំងឡាយដែលមានចែងពីមាត្រា ៣ ដល់មាត្រា ១៥ ព្រមទាំងមាត្រា ១៧ និងមាត្រា ១៨ នៃច្បាប់នេះ ត្រូវអនុវត្តចំពោះម៉ាកសមូហភាព ។

មាត្រា ១៧.-

បែបបទនៃការចុះបញ្ជីម៉ាកសមូហភាពមានដូចតទៅ :

ក- ពាក្យស្នើសុំចុះបញ្ជីម៉ាកសមូហភាពត្រូវបញ្ជាក់ថាជាម៉ាកសមូហភាព និងត្រូវភ្ជាប់មកជាមួយនូវបទបញ្ញារួមស្តីពីការគ្រប់គ្រង ការប្រើប្រាស់ម៉ាកសមូហភាពនោះមួយច្បាប់ ។

ខ- ម្ចាស់ម៉ាកសមូហភាព ដែលបានចុះបញ្ជីហើយ ត្រូវជូនដំណឹងទៅមន្ត្រីកាន់កាប់បញ្ជីអំពីការផ្លាស់ប្តូរទាំងឡាយតាមបទបញ្ញាដែលបានយោងក្នុងកថាខ័ណ្ឌ ក ។

មាត្រា ១៨.-

បន្ថែមលើខ្លឹមសារដូចមានចែងក្នុងមាត្រា ១៣ ចំណុច ក និងចំណុច ខ មន្ត្រីកាន់កាប់បញ្ជីត្រូវចាត់ទុកការចុះបញ្ជីម៉ាកសមូហភាពជាមោឃៈ ប្រសិនបើជនដែលទាមទារនូវមោឃភាពនោះបង្ហាញថា មានតែម្ចាស់ដែលបានចុះបញ្ជីម្នាក់ឯងប៉ុណ្ណោះដែលប្រើប្រាស់ម៉ាក ឬបង្ហាញថាម្ចាស់ដែលបានចុះបញ្ជីប្រើប្រាស់ ឬអនុញ្ញាតឱ្យប្រើប្រាស់វិលោភទៅនឹងបទបញ្ញារួមដែលបានបញ្ញត្តិនៅក្នុងមាត្រា ១៧ ចំណុច ក ឬបង្ហាញថាម្ចាស់ដែលបានចុះបញ្ជីអនុញ្ញាតឱ្យប្រើប្រាស់តាមរបៀបមួយដែលអាចបំភ័ន្តមជ្ឈដ្ឋានពាណិជ្ជកម្ម ឬសាធារណជនអំពីប្រភពដើម ឬលក្ខណៈរួមផ្សេងទៀតនៃទំនិញ ឬសេវាដែលពាក់ព័ន្ធ ។

## ជំពូកទី ៥

## ការផ្តល់អាជ្ញាប័ណ្ណចំពោះម៉ាក

មាត្រា ១៩.-

ការផ្តល់អាជ្ញាប័ណ្ណចំពោះម៉ាកត្រូវបានកំណត់ដូចខាងក្រោម :

ក- កិច្ចសន្យាអាជ្ញាប័ណ្ណណាមួយអំពីការចុះបញ្ជីម៉ាក ឬពាក្យស្នើសុំ

ទទួលស្គាល់កិច្ចសន្យាអាជ្ញាប័ណ្ណនោះ ត្រូវចែងអំពីការត្រួតពិនិត្យដោយមានប្រសិទ្ធភាពពីសំណាក់អ្នកប្រគល់អាជ្ញាប័ណ្ណ ចំពោះគុណភាពទំនិញ ឬសេវារបស់អ្នកទទួលអាជ្ញាប័ណ្ណដែលម៉ាកនោះត្រូវបានប្រើប្រាស់ ។ ប្រសិនបើកិច្ចសន្យាអាជ្ញាប័ណ្ណមិនបានចែងអំពីការត្រួតពិនិត្យគុណភាពនោះ ឬប្រសិនបើការត្រួតពិនិត្យគុណភាពនោះមិនត្រូវបានអនុវត្តដោយមានប្រសិទ្ធភាពទេ កិច្ចសន្យាអាជ្ញាប័ណ្ណនោះនឹងត្រូវចាត់ទុកជាមិនបានការ ។

ខ- ការចុះបញ្ជីម៉ាកសមូហភាពមួយ ឬពាក្យស្នើសុំចុះបញ្ជីម៉ាកសមូហភាពនោះមិនអាចជាកម្មវត្ថុនៃកិច្ចសន្យាអាជ្ញាប័ណ្ណបានឡើយ ។

## ជំពូកទី ៦

## ពាណិជ្ជនាម

**មាត្រា ២០.-**

នាម ឬសញ្ញាសំគាល់មិនអាចត្រូវបានប្រើប្រាស់ជាពាណិជ្ជនាមឡើយប្រសិនបើសារជាតិ ឬការប្រើប្រាស់នាម ឬសញ្ញាសំគាល់ដែលបានកំណត់នោះប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌ និងជាពិសេសអាចបំភាន់ដល់មជ្ឈដ្ឋានពាណិជ្ជកម្ម ឬសាធារណជន អំពីប្រភេទនៃសហគ្រាសដែលកំណត់ដោយនាមនោះ ។

**មាត្រា ២១.-**

ការការពារនិងការរំលោភលើពាណិជ្ជនាមត្រូវបានចែងដូចខាងក្រោម :

ក- ទោះជាច្បាប់ ឬបទបញ្ញាទាំងឡាយចែងអំពីកាតព្វកិច្ចក្នុងការចុះបញ្ជីពាណិជ្ជនាមក៏ដោយ ក៏នាមទាំងនោះត្រូវបានការពារប្រឆាំងនឹងទង្វើមិនស្របច្បាប់របស់ភាគីទីបី ទោះមុនការចុះបញ្ជី ឬគ្មានការចុះបញ្ជីក៏ដោយ ។

ខ- ការប្រើប្រាស់ពាណិជ្ជនាមជាបន្តបន្ទាប់ដោយភាគីទីបី ទោះបីជាពាណិជ្ជនាម ឬម៉ាក ឬជាម៉ាកសមូហភាព ឬការប្រើប្រាស់ណាមួយដែលអាចធ្វើឱ្យសាធារណជនភាន់ច្រឡំត្រូវចាត់ទុកថាមិនស្របច្បាប់ ។

## ជំពូកទី ៧
## អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

**មាត្រា ២២.-**

អំពើនៃការប្រកួតប្រជែងណាដែលផ្ទុយពីគោលការណ៍នៃការអនុវត្តទៀងត្រង់នៅក្នុងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្ម ត្រូវចាត់ទុកថាជាការប្រកួតប្រជែងមិនស្មោះត្រង់ ។

**មាត្រា ២៣.-**

ទង្វើទាំងឡាយដូចខាងក្រោមត្រូវចាត់ទុកថាបានបង្កើតនូវអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ :

**ក**- ការបង្កើតឱ្យមានការភាន់ច្រឡំតាមមធ្យោបាយណាមួយ ជាមួយសហគ្រាស ជាមួយទំនិញ ឬជាមួយសកម្មភាពឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្មនៃគូប្រកួតប្រជែង ។

**ខ**- ការពោលអះអាងមិនត្រឹមត្រូវក្នុងពាណិជ្ជកម្ម ដែលធ្វើឱ្យខូចកេរ្តិ៍ឈ្មោះសហគ្រាស ទំនិញ ឬសកម្មភាពឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្មនៃគូប្រកួតប្រជែង ។

**គ**- ការបញ្ជាក់ឬការពោលអះអាងដែលបានប្រើប្រាស់នៅក្នុងពាណិជ្ជកម្ម ហើយដែលអាចធ្វើឱ្យសាធារណជនភាន់ច្រឡំអំពីប្រភេទ ដំណើរការផលិត លក្ខណៈភាពសមស្របសំរាប់គោលបំណងរបស់គេ ឬបរិមាណនៃទំនិញ ។

## ជំពូកទី ៨
## ការរំលោភនិងវិធានការដោះស្រាយ

**មាត្រា ២៤.-**

ដោយផ្អែកតាមមាត្រា ១២ ខាងលើ ការរំលោភលើម៉ាកគឺជាការប្រព្រឹត្តដែលទាក់ទងទៅនឹងមាត្រា ១១ នៃច្បាប់នេះ ដោយជនណាម្នាក់ក្រៅពីម្ចាស់ម៉ាកដែល

បានចុះបញ្ជីរួចហើយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលពុំមានការយល់ព្រមពីម្ចាស់ម៉ាក ។

## មាត្រា ២៥.-

ការប្រើប្រាស់នូវសញ្ញាដូចឬប្រហាក់ប្រហែល ដែលធ្វើឱ្យភាន់ច្រឡំទៅនឹងម៉ាកល្បីដែលបានចុះបញ្ជីរួចហើយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការយល់ព្រមពីម្ចាស់នៃម៉ាកល្បី ជាការរំលោភលើម៉ាកល្បីនោះ ប្រសិនបើសញ្ញាទាំងនោះត្រូវបានយកមកប្រើប្រាស់ :

ក- ទាក់ទងទៅនឹងទំនិញនិងសេវា ដែលដូចឬប្រហាក់ប្រហែលនឹងទំនិញនិងសេវានៃម៉ាកល្បីដែលបានចុះបញ្ជីរួច ។

ខ- ទាក់ទងទៅនឹងទំនិញនិងសេវា ដែលមិនដូចឬមិនប្រហាក់ប្រហែលនឹងទំនិញនិងសេវានៃម៉ាកល្បីដែលបានចុះបញ្ជីរួច ហើយការប្រើប្រាស់នូវសញ្ញាទាក់ទងនឹងទំនិញឬសេវានោះបញ្ជាក់នូវការពាក់ព័ន្ធគ្នារវាងទំនិញនិងសេវានោះជាមួយនឹងម្ចាស់នៃម៉ាកល្បី ហើយដែលផលប្រយោជន៍នៃម្ចាស់ម៉ាកល្បីអាចនឹងត្រូវខូចខាតដោយការប្រើប្រាស់នោះ ។

## មាត្រា ២៦.-

ការប្រើប្រាស់នូវសញ្ញាដែលដូចឬប្រហាក់ប្រហែលនឹងម៉ាកល្បីដែលមិនបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការយល់ព្រមពីម្ចាស់នៃម៉ាកល្បី ជាការរំលោភលើម៉ាកល្បីនោះ ប្រសិនបើសញ្ញានោះត្រូវបានប្រើប្រាស់ទាក់ទងទៅនឹងទំនិញ ឬសេវាដូច ឬប្រហាក់ប្រហែលនឹងទំនិញឬសេវានៃម៉ាកល្បីនោះ ។

## មាត្រា ២៧.-

តាមសំណើរបស់ម្ចាស់ម៉ាក ឬអ្នកទទួលអាជ្ញាប័ណ្ណ តុលាការអាចចេញនូវសេចក្ដីសម្រេចបណ្ដោះអាសន្នមួយដើម្បីទប់ស្កាត់ការរំលោភ ការដែលនឹងមានការ

វិលោភ ឬទង្វើដែលមិនស្របច្បាប់ដូចមានចែងក្នុងមាត្រា ២១ មាត្រា ២២ និងមាត្រា ២៣ និងសម្រេចឱ្យសងការខូចខាត ហើយផ្តល់នូវដំណោះស្រាយផ្សេងៗ ដែលមានចែងក្នុងច្បាប់ជាធរមាន ។ ប្រសិនបើអ្នកទទួលអាជ្ញាប័ណ្ណបានស្នើទៅម្ចាស់ម៉ាកឱ្យប្តឹងទៅតុលាការ ដើម្បីឱ្យជួសជុលនូវសំណងដីជាក់លាក់មួយ ប៉ុន្តែបើម្ចាស់ម៉ាក បានបដិសេធ ឬខកខានមិនបានធ្វើតាម អ្នកទទួលអាជ្ញាប័ណ្ណអាចប្តឹងទៅតុលាការដោយផ្ទាល់បាន ។

**មាត្រា ២៨.-**

តាមសំណើរបស់អាជ្ញាធរមានសមត្ថកិច្ចណាមួយ ឬជនណាមួយដែលមានការពាក់ព័ន្ធដូចជា សមាគម ឬសហជីពនៃផលិតករ ឧស្សាហករ ឬពាណិជ្ជករ តុលាការអាចសំរេចឱ្យមានការជួសជុលសំណង ចំពោះករណីនៃការប្រកួតប្រជែងមិនស្មោះត្រង់ដូចមានចែងនៅក្នុងមាត្រា ២២ និងមាត្រា ២៣ ។

## ជំពូកទី ៩

## វិធានការបណ្តោះអាសន្ន

**មាត្រា ២៩.-**

តាមសំណើរបស់អ្នកប្តឹង តុលាការមានអំណាចដាក់ចេញនូវវិធានការបណ្តោះអាសន្នជាបន្ទាន់និងមានប្រសិទ្ធភាព ដើម្បីទប់ស្កាត់ការរំលោភ ការរំលោភដែលប្រុងនឹងកើតមាន ឬរក្សាទុកនូវភស្តុតាងដែលពាក់ព័ន្ធ ។

**មាត្រា ៣០.-**

នៅពេលចាំបាច់ ជាពិសេសនៅពេលការយឺតយ៉ាវអាចបណ្តាលឱ្យមានភាពអន្តរាយដែលមិនអាចជួសជុលបានចំពោះម្ចាស់សិទ្ធិ ឬនៅពេលដែលភស្តុតាងអាចនឹងត្រូវបំផ្លាញ តុលាការអាចដាក់ចេញនូវវិធានការបណ្តោះអាសន្ន ប្រសិនបើដើមចោទផ្តល់នូវ :

ក- ភ័ស្តុតាងត្រឹមត្រូវដែលមាន ដែលអាចធ្វើឱ្យតុលាការយល់ស្របក្នុងកម្រិតមួយគ្រប់គ្រាន់សម្រាប់សន្និដ្ឋានបញ្ជាក់ថា ដើមចោទគឺជាម្ចាស់ពិតប្រាកដ ហើយសិទ្ធិរបស់អ្នកប្តឹងកំពុងត្រូវបានគេរំលោភ ឬការរំលោភនោះ អាចនឹងកើតមានឡើងក្នុងពេលឆាប់ៗ ។

ខ- ប្រាក់កក់ធានាដែលតម្រូវ ឬការធានាដែលមានតម្លៃស្មើនៃប្រាក់កក់គ្រប់គ្រាន់ក្នុងការការពារចុងចម្លើយនិងទប់ស្កាត់មិនឱ្យមានការរំលោភបំពាន ។ ប្រាក់កក់ធានានេះ ត្រូវស្ថិតនៅក្រោមការកំណត់របស់តុលាការ ។

**មាត្រា ៣១.-**

នៅពេលដែលវិធានការបណ្តោះអាសន្នត្រូវបានដាក់ចេញ តុលាការត្រូវជូនដំណឹងដល់ចុងចម្លើយ អំពីសេចក្តីសម្រេចស្តីពីការចាត់វិធានការបណ្តោះអាសន្ននោះ ។

**មាត្រា ៣២.-**

នៅពេលដែលវិធានការបណ្តោះអាសន្ន ត្រូវបានដាក់ចេញតាមមាត្រា ៣០ និងមាត្រា ៣១ ចុងចម្លើយអាចដាក់ពាក្យបណ្តឹងទៅតុលាការស្នើសុំឱ្យពិនិត្យវិធានការនោះឡើងវិញក្នុងរយៈពេល ១៥ ( ដប់ប្រាំ ) ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ។ តុលាការត្រូវផ្តល់នូវឱកាសសវនាការឱ្យដល់ភាគីដែលពាក់ព័ន្ធ ហើយត្រូវពិនិត្យវិធានការនោះឡើងវិញនិងតម្កល់ កែតម្រូវ ឬលុបចោលនូវសេចក្តីសម្រេចរបស់ខ្លួនក្នុងរយៈពេលមួយសមស្របតាមច្បាប់កំណត់ ។

**មាត្រា ៣៣.-**

ក្នុងករណីដើមចោទ នៅក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ នៃថ្ងៃធ្វើការគិតពីថ្ងៃបានទទួលដំណឹងអំពីការដាក់ចេញនូវវិធានការបណ្តោះអាសន្នហើយ ឬនៅ ក្នុងរយៈពេលមួយសមស្របដែលកំណត់ដោយតុលាការនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ពុំបានផ្តួចផ្តើមបន្តសំណុំរឿងបណ្តឹងដែលនាំដល់សេចក្តីសម្រេចអំពីអង្គសេចក្តីនៃករណី

តុលាការត្រូវលុបនូវវិធានការបណ្តោះអាសន្ននោះចោលវិញ ដោយផ្អែកតាមសំណើរបស់ចុងចម្លើយ ។

មាត្រា ៣៤.-

ក្នុងករណីដែលវិធានការបណ្តោះអាសន្នត្រូវបានលុបចោលវិញ ឬក្នុងករណីដែលតុលាការសម្រេចនូវអង្គសេចក្តីនៃករណីតាមដំណាក់ការជំរះក្តីស្របតាមមាត្រា ៣៣ តាមការផ្តួចផ្តើមរបស់ដើមចោទ ប៉ុន្តែបែរជាគ្មានការរំលោភ ឬការគំរាមរំលោភវិញ ដោយយោងតាមសំណើរបស់ចុងចម្លើយ តុលាការត្រូវសម្រេចឱ្យដើមចោទសងឱ្យចុងចម្លើយនូវសំណងសមស្របចំពោះការខូចខាតនានាដែលកើតមានឡើងដោយការអនុវត្តនូវវិធានការបណ្តោះអាសន្ននោះ ។

## ជំពូកទី ១០
## វិធានការតាមមាត់ច្រកព្រំដែន

មាត្រា ៣៥.-

ម្ចាស់ម៉ាកដែលបានចុះបញ្ជីហើយអាចធ្វើពាក្យបណ្តឹងទៅរដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការឱ្យឃុំទុកនូវការធ្វើបែបបទទំនិញណាដែលសង្ស័យថាមានម៉ាកក្លែងក្លាយដោយបង្ហាញនូវភស្តុតាងច្បាស់លាស់ថា គាត់ជាម្ចាស់នៃម៉ាកដែលបានចុះបញ្ជី ។

មាត្រា ៣៦.-

ពាក្យបណ្តឹងទាំងឡាយដែលបានលើកនៅក្នុងមាត្រា ៣៥ ត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងត្រូវអមដោយ :

ក- វិញ្ញាបនប័ត្រចុះបញ្ជីម៉ាក ។

ខ- សេចក្តីថ្លែងពីមូលហេតុនៃការប្តឹងនិងជាពិសេសភស្តុតាងដំបូងដែលបង្ហាញថា ទំនិញនោះពាក់ម៉ាកក្លែងក្លាយមែន ។

គ- ការរៀបរាប់ដ៏ល្អិតល្អន់ពីទំនិញដែលម៉ាករបស់វាត្រូវបានប្រើប្រាស់ព្រមទាំងគំរូនៃផលិតផលពិតប្រាកដផង ប្រសិនបើមានសំណូមពរ ។

ឃ- ឈ្មោះនិងអាស័យដ្ឋានរបស់អ្នកប្តឹងនិងតំណាងរបស់គេដែលត្រូវរៀបរាប់ឱ្យបានសព្វគ្រប់តាមការកំណត់ ។

ង- លិខិតអនុញ្ញាតពីម្ចាស់ម៉ាកដែលបានចុះបញ្ជី ប្រសិនបើពាក្យបណ្តឹងនោះត្រូវបានដាក់ដោយតំណាងដែលទទួលសិទ្ធិ ។

ច- កម្រៃរដ្ឋបាលតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៣៧.-**

ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលនូវពាក្យបណ្តឹងតាមមាត្រា ៣៥ រដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងទៅអ្នកប្តឹងថា ពាក្យបណ្តឹងរបស់ខ្លួនត្រូវបានទទួលស្គាល់ថាត្រឹមត្រូវ ឬបដិសេធ ឬមួយរក្សាទុកសម្រាប់ពិចារណានៅពេលក្រោយ ។

**មាត្រា ៣៨.-**

រដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀតដែលកំណត់ដោយអនុក្រឹត្យ មានសិទ្ធិស្នើឱ្យអ្នកប្តឹងបង់ប្រាក់ធានា ឬតម្រូវឱ្យមានការធានាដែលមានតំលៃស្មើនៃប្រាក់កក់គ្រប់គ្រាន់ សម្រាប់ការពារអ្នកនាំចូល អ្នកទទួល អ្នកនាំចេញ ឬម្ចាស់ទំនិញនិងអាជ្ញាធរមានសមត្ថកិច្ច ។ ប្រាក់ធានា ឬការធានាដែលមានតម្លៃស្មើនៃប្រាក់កក់នេះត្រូវបានកំណត់តាមរបៀបនិងបែបបទមួយដែលមិនត្រូវឱ្យរារាំងដល់ការអនុវត្តនីតិវិធីនេះដោយមិនសមហេតុផល ។

**មាត្រា ៣៩.-**

ក្នុងពេលយល់ព្រមតាមពាក្យបណ្តឹងក្នុងមាត្រា ៣៥ រដ្ឋបាលគយនិងរដ្ឋាករត្រូវព្យួរទុកនូវការធ្វើបែបបទទំនិញដែលមានទាក់ទងទៅនឹងពាក្យបណ្តឹង ។ ការព្យួរទុកនេះត្រូវនៅជាធរមានក្នុងរយៈពេលដំបូងនិងក្នុងរយៈពេលដែលបានពន្យារមិនលើសពី

១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ។ រដ្ឋបាលគយនិងរដ្ឋាករត្រូវជូនពត៌មានភ្លាមទៅអ្នកនាំចូលនិងអ្នកប្តឹងអំពីការល្បរទុកនូវការធ្វើបែបបទទំនិញ ហើយត្រូវបញ្ជាក់ពីមូលហេតុនៃការល្បរទុកនេះផង ។ រដ្ឋបាលគយនិងរដ្ឋាករត្រូវជូនដំណឹងពីឈ្មោះនិងអាស័យដ្ឋាននៃអ្នកប្តឹងដល់អ្នកនាំចូលផងដែរ ។

## មាត្រា ៤០.-

ក្នុងរយៈពេលមិនហួសពី ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពេលដែលអ្នកប្តឹងបានទទួលនូវពត៌មានអំពីការឃាត់ទំនិញ ប្រសិនបើរដ្ឋបាលគយនិងរដ្ឋាករបានទទួលនូវពត៌មានថា ចំណាត់ការដែលនាំដល់ការសម្រេចនូវអង្គសេចក្តីនៃករណីមិនត្រូវបានផ្តួចផ្តើមឡើងដោយភាគីមួយទៀតផ្សេងពីចុងចម្លើយ ឬថាអាជ្ញាធរដែលបានប្រគល់សិទ្ធិត្រឹមត្រូវមិនបានអនុវត្តនូវវិធានការបណ្តោះអាសន្ន ដើម្បីពន្យារការដោះលែងទំនិញទេ ទំនិញនោះនឹងត្រូវដោះលែងតែក្នុងករណីដែលល័ក្ខខ័ណ្ឌផ្សេងៗទៀតសម្រាប់ការនាំចូល ឬនាំចេញត្រូវបានគោរព ។

ក្នុងករណីសមស្រប រយៈពេលនេះអាចត្រូវពន្យារ ១០ (ដប់) ថ្ងៃទៀតនៃថ្ងៃធ្វើការ ។

ប្រសិនបើចំណាត់ការ ដែលនាំឱ្យមានការសម្រេចនូវអង្គសេចក្តីនៃករណីត្រូវបានផ្តួចផ្តើមឡើង ការពិនិត្យឡើងវិញមានទាំងការធ្វើសវនាការផង ត្រូវបានរៀបចំឡើងតាមការស្នើសុំពីសំណាក់ចុងចម្លើយដើម្បីសម្រេចនៅក្នុងរយៈពេលមួយសមស្របថា តើវិធានការនេះត្រូវតម្កល់ កែតម្រូវ ឬលុបចោល ។

## មាត្រា ៤១.-

អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធមានសិទ្ធិសម្រេចឱ្យអ្នកប្តឹងសងទៅម្ចាស់អ្នកនាំចូល អ្នកនាំចេញនិងអ្នកទទួលទំនិញនូវសំណងសមស្របចំពោះការខូចខាតរបស់គេដែលបណ្តាលមកពីការឃាត់ទំនិញដោយមិនត្រឹមត្រូវ ឬការឃាត់ទំនិញដូចមានចែងក្នុងមាត្រា ៣៩ ។ ក្នុងករណីភាគីណាមួយមិនយល់ព្រមតាមសេចក្តីសម្រេចនោះភាគីនោះមានសិទ្ធិប្តឹងទៅតុលាការ ។

មាត្រា ៤២.-

រដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀតអាចអនុញ្ញាតឱ្យម្ចាស់សិទ្ធិអ្នកនាំចូល ឬអ្នកនាំចេញពិនិត្យទំនិញដែលបានល្បួរទុកតាមបែបបទគយ ដូចមានចែងក្នុងមាត្រា ៣៩ និងដកយកនូវគំរូដើម្បីពិនិត្យសាកល្បងនិងវិភាគ ក្នុងគោលបំណងបញ្ជាក់ឱ្យដឹងថាទំនិញនោះពាក់ម៉ាកក្លែងក្លាយ ឬមិនក្លែងក្លាយ ។

នៅពេលដែលទំនិញត្រូវបានបញ្ជាក់ឱ្យដឹងថាជាទំនិញពាក់ម៉ាកក្លែងក្លាយ រដ្ឋបាលគយនិងរដ្ឋាករអាចជូនពត៌មានទៅម្ចាស់សិទ្ធិនូវឈ្មោះនិងអាស័យដ្ឋាននៃអ្នកនាំចេញ អ្នកនាំចូល អ្នកទទួលនិងបរិមាណទំនិញ ។ ដោយមិនឱ្យប៉ះពាល់ដល់ការការពារនូវពត៌មានសម្ងាត់ រដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀតអាចផ្តល់ទៅឱ្យម្ចាស់សិទ្ធិនូវច្បាប់ចម្លងនៃឯកសារទំនិញទាំងនោះ ឬនូវពត៌មានដែលមាន ឬឯកសារដែលទាក់ទងទៅនឹងការនាំចូលឬនាំចេញនូវទំនិញប្រហាក់ប្រហែលពីមុនដោយអ្នកនាំចូល ឬអ្នកនាំចេញដដែលនេះតាមសំណូមពររបស់ម្ចាស់សិទ្ធិ ។

មាត្រា ៤៣.-

រដ្ឋបាលគយនិងរដ្ឋាករអាចល្បួរទុកនូវការធ្វើបែបបទទំនិញដែលពាក់ម៉ាកក្លែងក្លាយ ដែលខ្លួនបានពិនិត្យឃើញមានភស្តុតាងជាលើកដំបូងថា កំពុងតែមានឬអាចនឹងមានការនាំចូលនូវទំនិញប្រភេទនេះ ។

មាត្រា ៤៤.-

រដ្ឋបាលគយនិងរដ្ឋាករត្រូវជូនពត៌មានភ្លាមទៅឱ្យម្ចាស់សិទ្ធិ អំពីទីកន្លែងនិងថ្ងៃដែលល្បួរទុកនូវការធ្វើបែបបទរបស់គយ ហើយរដ្ឋបាលគយនិងរដ្ឋាករក៏អាចស្នើឱ្យម្ចាស់សិទ្ធិផ្តល់នូវពត៌មានទាំងឡាយដែលអាចជាជំនួយក្នុងការអនុវត្តនូវអំណាចរបស់ខ្លួនផងដែរ ។

មាត្រា ៤៥.-

ដោយអនុលោមទៅនឹងបញ្ញត្តិដែលមានចែងក្នុងមាត្រា ៤២ នៃច្បាប់នេះ

អាជ្ញាធរសាធារណៈនិងមន្ត្រីទទួលបន្ទុកត្រូវបានលើកលែងពីការទទួលខុសត្រូវចំពោះវិធានការដោះស្រាយដោយសមស្រប នៅពេលដែលសកម្មភាពទាំងនោះត្រូវបានធ្វើ ឬមានបំណងនឹងធ្វើដោយស្មោះត្រង់ ។

**មាត្រា ៤៦.-**

រដ្ឋបាលគយនិងរដ្ឋាករនិងអាជ្ញាធរមានសមត្ថកិច្ច តាមរយៈសេចក្ដីសម្រេចរបស់តុលាការមានសិទ្ធិបំផ្លាញចោលនូវទំនិញដែលពាក់ម៉ាកក្លែងក្លាយនោះ ។ រដ្ឋបាលគយនិងរដ្ឋាករ មិនត្រូវអនុញ្ញាតឱ្យធ្វើការនាំចេញបន្តនូវទំនិញដែលមានម៉ាកក្លែងក្លាយ ឬដាក់ទំនិញនេះឱ្យនៅក្រោមនីតិវិធីផ្សេងទៀតរបស់គយឡើយ ។

**មាត្រា ៤៧.-**

ទំនិញពាក់ម៉ាកក្លែងក្លាយដែលមិនមានលក្ខណៈពាណិជ្ជកម្ម ដែលនៅក្នុងអីវ៉ាន់ផ្ទាល់ខ្លួននៃអ្នកដំណើរអាចស្ថិតនៅក្រៅការអនុវត្តនៃច្បាប់នេះ ។

## ជំពូកទី ១១
## ការប្ដូរម្ចាស់កម្មសិទ្ធិ

**មាត្រា ៤៨.-**

តាមសំណើរបស់ភាគីដែលពាក់ព័ន្ធមកមន្ត្រីកាន់កាប់បញ្ជី ការប្ដូរម្ចាស់កម្មសិទ្ធិណាមួយនៃការចុះបញ្ជីម៉ាកត្រូវសរសេរជាលាយលក្ខណ៍អក្សរ ហើយត្រូវបានចុះបញ្ជីនិងចុះផ្សាយដោយមន្ត្រីកាន់កាប់បញ្ជី ។ ការប្ដូរបែបនេះនឹងមិនមានអានុភាព ចំពោះភាគីទីបីឡើយ រហូតដល់ការចុះបញ្ជីត្រូវបានធ្វើរួចជាស្ថាពរ ។

**មាត្រា ៤៩.-**

ការប្ដូរម្ចាស់កម្មសិទ្ធិណាមួយនៃការចុះបញ្ជីម៉ាកសមូហភាព តម្រូវឱ្យមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មជាមុន ។

**មាត្រា ៥០.-**

ការប្តូរម្ចាស់កម្មសិទ្ធិណាមួយនៃពាណិជ្ជនាម ត្រូវធ្វើឡើងដោយការផ្ទេរសហគ្រាសទាំងមូល ឬមួយផ្នែកហើយត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

**មាត្រា ៥១.-**

ការប្តូរម្ចាស់កម្មសិទ្ធិនៃការចុះបញ្ជីម៉ាកត្រូវចាត់ទុកជាមោឃៈ ប្រសិនបើម៉ាកនោះទំនងជាមានលក្ខណៈបោកបញ្ឆោត ឬបណ្តាលឱ្យមានការភាន់ច្រឡំ ជាពិសេសចំពោះប្រភេទ ប្រភពដើម ដំណើរការផលិតកម្ម ចរិតលក្ខណៈ ភាពសមស្របដើម្បីគោលបំណងនៃទំនិញ ឬសេវាដែលម៉ាកនោះបម្រុងប្រើប្រាស់ ឬកំពុងប្រើប្រាស់ ។

**មាត្រា ៥២.-**

កិច្ចសន្យាអាជ្ញាប័ណ្ណណាមួយពាក់ព័ន្ធនឹងម៉ាកដែលបានចុះបញ្ជីរួចហើយ ឬពាក្យស្នើសុំទទួលស្គាល់កិច្ចសន្យា ត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជីដែលត្រូវរក្សាការសម្ងាត់ចំពោះខ្លឹមសារនៃកិច្ចសន្យានោះ ប៉ុន្តែត្រូវចុះបញ្ជីនិងចុះផ្សាយនូវពត៌មានដែលពាក់ព័ន្ធ ។ កិច្ចសន្យាអាជ្ញាប័ណ្ណនឹងមិនមានអានុភាពចំពោះភាគីទីបីឡើយរហូតដល់ការចុះបញ្ជីនោះត្រូវបានធ្វើរួចជាស្ថាពរ ។

## ជំពូកទី ១២
## ការកាន់កាប់បញ្ជីម៉ាក

**មាត្រា ៥៣.-**

ក្រសួងពាណិជ្ជកម្មមានតួនាទីបំពេញភារកិច្ចដែលទាក់ទងទៅនឹងនីតិវិធីដើម្បីធ្វើការចុះបញ្ជីម៉ាក និងដើម្បីធ្វើការគ្រប់គ្រងម៉ាកដែលបានចុះបញ្ជីរួចហើយ ដូចបានបញ្ជាក់នៅក្នុងច្បាប់នេះនិងនៅក្នុងបទបញ្ញាទាំងឡាយ ។

**មាត្រា ៥៤.-**

ក្រសួងពាណិជ្ជកម្ម ជាស្ថាប័នមានសមត្ថកិច្ចកាន់កាប់និងចុះបញ្ជីម៉ាក ។ ម៉ាកសមូហភាពនឹងត្រូវចុះបញ្ជីនៅក្នុងផ្នែកពិសេសមួយនៃបញ្ជីម៉ាក ។ គ្រប់ការកត់ត្រាដែលមានចែងនៅក្នុងច្បាប់នេះ ត្រូវធ្វើនៅក្នុងបញ្ជីខាងលើ ។

ជនណាក៏ដោយក៏អាចមានសិទ្ធិសុំមើលបញ្ជីម៉ាកបានដែរ ហើយអាចដកស្រង់ចេញពីបញ្ជីនោះនូវពត៌មានផ្សេងៗ ដែលស្របទៅតាមល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងបទបញ្ជា ។

**មាត្រា ៥៥.-**

ក្រសួងពាណិជ្ជកម្មត្រូវបោះពុម្ពនៅក្នុងព្រឹត្តិប័ត្រផ្លូវការនូវគ្រប់ការចុះបញ្ជី ការចុះបញ្ជីសាឡើងវិញ ការបដិសេធ ការលុបម៉ាកចេញពីបញ្ជីនិងការងារផ្សេងៗទៀតដែលកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥៦.-**

តាមប្រការទាំងឡាយនៃបទបញ្ជា មន្ត្រីកាន់កាប់បញ្ជីអាចកែតម្រូវកំហុសផ្សេងៗនៅក្នុងការកត់ត្រាដែលបានធ្វើឡើង ដោយអនុលោមតាមច្បាប់នេះ ឬតាមបទបញ្ជាទាំងឡាយ ។

នៅពេលទទួលសំណើជាលាយល័ក្ខណ៍អក្សរហើយ ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីយល់ថាជាការត្រឹមត្រូវដើម្បីធ្វើដូច្នោះ មន្ត្រីកាន់កាប់បញ្ជីអាចបន្តពេលវេលាសម្រាប់អនុវត្តសកម្មភាពណាមួយ ឬប្រកាន់យកនូវចំណាត់ការណាមួយតាមច្បាប់នេះ និងតាមបទបញ្ជាទាំងឡាយ ដោយជូនដំណឹងដល់ភាគីពាក់ព័ន្ធនិងតាមល័ក្ខខ័ណ្ឌដែលមន្ត្រីកាន់កាប់បញ្ជីដាក់បញ្ជាឱ្យ ។ ការបន្តនេះអាចត្រូវយល់ព្រម ទោះបីរយៈពេលអនុវត្តនូវសកម្មភាព ឬប្រកាន់យកនូវចំណាត់ការត្រូវផុតកំណត់ហើយក៏ដោយ ។

**មាត្រា ៥៧.-**

មន្ត្រីកាន់កាប់បញ្ជីត្រូវផ្តល់នូវឱកាសសម្រាប់សវនាការដល់ភាគីណាមួយនៃបណ្តឹងនៅចំពោះមុខខ្លួនមុនពេលអនុវត្តអំណាចឆន្ទានុសិទ្ធិ ដែលបានប្រគល់ឱ្យដោយច្បាប់នេះនិងដោយបទបញ្ជាទាំងឡាយប្រឆាំងចំពោះភាគីនោះ ។

## ជំពូកទី ១៣

## ភ្នាក់ងារ

**មាត្រា ៥៨.-**

ក្នុងករណីដែលលំនៅដ្ឋានអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្មសំខាន់របស់អ្នកស្នើសុំស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជា អ្នកស្នើសុំនោះត្រូវមានតំណាងជាភ្នាក់ងារដែលមានទីលំនៅ និងកំពុងប្រកបវិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥៩.-**

អ្នកតំណាងដែលជាភ្នាក់ងារក្នុងការដាក់ពាក្យសុំចុះបញ្ជីម៉ាកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដូចមានចែងនៅក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

## ជំពូកទី ១៤

## ការអនុវត្តសន្ធិសញ្ញាអន្តរជាតិនិងការបកស្រាយ

**មាត្រា ៦០.-**

បទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញាអន្តរជាតិ អំពីកម្មសិទ្ធិឧស្សាហកម្មដែលព្រះរាជាណាចក្រកម្ពុជាជាភាគីមួយនៃសន្ធិសញ្ញានោះ ត្រូវយកមកអនុវត្តជាមួយនឹងច្បាប់នេះបានផងដែរ ។

ក្នុងករណីមានទំនាស់ជាមួយនឹងមាត្រាទាំងឡាយនៃច្បាប់នេះ បទប្បញ្ញត្តិនៃសន្ធិសញ្ញាអន្តរជាតិទាំងនោះត្រូវចាត់ទុកជាបទប្បញ្ញត្តិគោល ។

**មាត្រា ៦១.-**

នៅក្នុងច្បាប់នេះ :

**-ចំណាត់ថ្នាក់អន្តរជាតិ** មានន័យថា ចំណាត់ថ្នាក់ដែលអនុលោមតាមកិច្ចព្រមព្រៀងទីក្រុងនីស ដែលចែងអំពីចំណាត់ថ្នាក់អន្តរជាតិនៃទំនិញនិងសេវាកម្មសម្រាប់គោលបំណងនៃការចុះបញ្ជីម៉ាក ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ១៩៥៧ ដែលបានកែសម្រួលនៅពេលចុងក្រោយ

**-អនុសញ្ញាទីក្រុងប៉ារីស** មានន័យថា អនុសញ្ញាដែលបានចុះហត្ថលេខានៅទីក្រុងប៉ារីស ស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៨៨៣ ដែលបានកែសំរួលនៅពេលចុងក្រោយ

**-កាលបរិច្ឆេទអាទិភាព** មានន័យថា ពេលវេលានៃការស្នើសុំមុនគេដែលប្រើប្រាស់ជាមូលដ្ឋានសម្រាប់ទទួលនូវសិទ្ធិអាទិភាព ដូចមានចែងនៅក្នុងអនុសញ្ញាទីក្រុងប៉ារីស

**-បទបញ្ជា** មានន័យថា ប្រកាសឬសេចក្តីណែនាំដែលចេញដោយក្រសួងពាណិជ្ជកម្ម

**-ទំនិញដែលពាក់ម៉ាកក្លែងក្លាយ** មានន័យថា ទំនិញទាំងឡាយរួមទាំងសំបកវេចខ្ចប់ផងដែលមានម៉ាកដូចគ្នានឹងម៉ាកដែលបានចុះបញ្ជីត្រឹមត្រូវទាក់ទងទៅនឹងទំនិញនោះដោយគ្មានការអនុញ្ញាត ឬមិនអាចសំគាល់បាននូវលក្ខណៈខុសគ្នាពីទិដ្ឋភាពសំខាន់ៗនៃម៉ាក និងដែលរំលោភបំពានសិទ្ធិរបស់ម្ចាស់ម៉ាកស្របច្បាប់ក្រោមច្បាប់នៃប្រទេសនាំចូល ។

## ជំពូកទី ១៥

## ទោសប្បញ្ញត្តិ

**មាត្រា ៦២.-**

សេចក្តីសម្រេចរបស់ក្រសួងពាណិជ្ជកម្ម អាចជាកម្មវត្ថុនៃការប្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចបាន ដោយភាគីជំទាស់ណាមួយ ហើយបណ្តឹងតវ៉ានេះត្រូវធ្វើក្នុង

រយៈពេល ៣ (បី) ខែ គិតចាប់ពីថ្ងៃចេញសេចក្ដីសម្រេច ។

**មាត្រា ៦៣.-**

ជនណាដែលផ្ដល់ពត៌មានមិនពិតដល់មន្ត្រីកាន់កាប់បញ្ជីក្នុងការដាក់ពាក្យស្នើសុំបណ្ដឹងជំទាស់ ឬឯកសារដទៃដែលបានតម្កល់ទុកទាក់ទិននឹងការស្នើសុំចុះបញ្ជី ការកែតម្រូវនៃការចុះបញ្ជី ការចុះបញ្ជីសាជាថ្មី ការលុបចោលនូវការចុះបញ្ជី ម៉ាក ពាណិជ្ជនាម ឬកិច្ចសន្យាផ្ដល់អាជ្ញាប័ណ្ណដែលទាក់ទងនឹងម៉ាក ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ដល់ ៥.០០០.០០០ (ប្រាំលាន) រៀល និងត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ ឬទោសណាមួយនៃទោសទាំងពីរនេះ ។

**មាត្រា ៦៤.-**

ជនណាដែលក្លែងបន្លំ ពាណិជ្ជសញ្ញា សេវាសញ្ញា ម៉ាកសមូហភាព ឬពាណិជ្ជ-នាមរបស់សហគ្រាសមួយផ្សេងទៀត ដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចមានចែងនៅមាត្រា ១១ ចំណុច ខ ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ដល់ ២០.០០០.០០០ (ម្ភៃលាន) រៀល និងត្រូវផ្ដន្ទាទោសដាក់ពន្ធ-នាគារពី ១ (មួយ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ឬទោសណាមួយនៃទោសទាំងពីរនេះ ។

**មាត្រា ៦៥.-**

ជនណាដែលធ្វើត្រាប់តាម ពាណិជ្ជសញ្ញា សេវាសញ្ញា ម៉ាកសមូហភាព ឬពាណិជ្ជនាមរបស់សហគ្រាសមួយ ដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងបំភាន់សាធារណជនឱ្យជឿថា ពាណិជ្ជសញ្ញា សេវាសញ្ញា ម៉ាកសមូហភាព ឬពាណិជ្ជនាមទាំងនោះជារបស់សហគ្រាសមួយផ្សេងទៀត ដូចមានចែងក្នុងមាត្រា ២៣ ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ ប្រាំលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ដល់ ១ (មួយ) ឆ្នាំ ឬទោសណាមួយនៃទោសទាំងពីរនេះ ។

## មាត្រា ៦៦.-

ជនណាដែលនាំចូល លក់ ប្រកាសលក់ ឬមានបំណងលក់ដោយចេតនា នូវទំនិញដែលមានម៉ាកក្លែងបន្លំ ឬមានចេតនាផ្តល់សេវាចំពោះសេវាសញ្ញា ម៉ាកសមូហភាព ឬពាណិជ្ជនាមក្លែងបន្លំត្រូវផ្តន្ទាទោសតាមបទប្បញ្ញត្តិនៃមាត្រា ៦៤ នៃច្បាប់នេះ ។

ជនណាដែលនាំចូល លក់ ប្រកាសលក់ ឬមានបំណងលក់ដោយចេតនា នូវទំនិញដែលមានម៉ាកត្រាប់តាមគេ ត្រូវផ្តន្ទាទោសតាមបទប្បញ្ញត្តិនៃមាត្រា ៦៥ នៃច្បាប់នេះ ។

## មាត្រា ៦៧.-

ក្នុងករណីមិនរាងចាលចំពោះបទល្មើសនឹងមាត្រា ៦៤ ឬមាត្រា ៦៥ នៃច្បាប់នេះត្រូវផ្តន្ទាទោសទ្វេឡើងទាំងទោសពិន័យជាប្រាក់ ទាំងទោសដាក់ពន្ធនាគារ ដែលមានបញ្ញត្តិនៅក្នុងមាត្រានោះ ។

## មាត្រា ៦៨.-

ក្នុងករណីជនល្មើសដែលទទួលខុសត្រូវចំពោះច្បាប់នេះ ជានីតិបុគ្គល នាយកគ្រប់គ្រង អ្នកចាត់ការ ឬតំណាងនៃនីតិបុគ្គលនោះក៏ត្រូវទទួលទណ្ឌកម្មដូចដែលបានចែងសម្រាប់បទល្មើសនោះដែរ លើកលែងតែគេអាចបង្ហាញភស្តុតាងតាមរយៈនីតិបុគ្គលថាគេពុំបានដឹងឮ ឬយល់ស្របនឹងបទល្មើសនោះឡើយ ។

## មាត្រា ៦៩.-

ទំនិញទាំងឡាយដែលបាននាំចូល លក់ ផ្តល់ឱ្យសម្រាប់លក់ ឬមានគោលបំណងលក់ដោយមិពានច្បាប់នេះ ដូចមានចែងក្នុងមាត្រា ៦៦ ត្រូវរឹបអូស ឬនិងបំផ្លាញចោលតាមសេចក្តីសម្រេចរបស់តុលាការ ទោះជាមាន ឬគ្មានអ្នកណាម្នាក់ត្រូវបានជាប់ទោសចំពោះបទល្មើសនេះក៏ដោយ ។

**មាត្រា ៧០.-**

ជនណាដែលបានជំរិត ឬបានទទួលនូវរបស់ ឬប្រាក់ ដោយប្រើអំណាចនៃមុខងាររបស់ខ្លួន ជននោះត្រូវចាត់ទុកថា បានប្រព្រឹត្តបទល្មើសហើយនឹងត្រូវផ្តន្ទាទោស តាមច្បាប់ជាធរមាន ។

## ជំពូកទី ១៦

## អវសានប្បញ្ញត្តិ

**មាត្រា ៧១.-**

ម៉ាកដែលបានចុះបញ្ជីហើយ ត្រូវបានទទួលការចុះបញ្ជីសាជាថ្មីដោយស្របច្បាប់ក្នុងរយៈពេលដូចគ្នានឹងមាត្រា១១ និងមាត្រា១២ ។ នៅពេលចុះបញ្ជីសាជាថ្មីមុខទំនិញត្រូវតែរៀបចំឡើងវិញឱ្យស្របទៅតាមចំណាត់ថ្នាក់អន្តរជាតិ។

នោះបីជាបទបញ្ញាទាំងឡាយដែលមានកន្លងមក ត្រូវទុកជានិរាករណ៍ក៏ដោយក៏ម៉ាកដែលបានចុះបញ្ជីក្រោមបទបញ្ញាទាំងឡាយនោះត្រូវនៅជាធរមាន ហើយអនុលោមតាមកថាខ័ណ្ឌ ទី ១ នៃមាត្រានេះ ត្រូវចាត់ទុកថាបានចុះបញ្ជីតាមច្បាប់នេះ ។

**មាត្រា ៧២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២

**ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

ចរល.០២.០២.០០៣៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ហត្ថលេខា**

**ចម ប្រសិទ្ធ**

លេខ: ៤០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible] ណាឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០២០២/០៥០

**យើង**

**ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

**តែងតាំង**

**លោក ថូង អ៊ុយប៉ាង**

**ជា**

**ឧកញ៉ា**

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០២

៣រល.០២.០២.០០៦០

លេខ : ៥៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ[illegible] ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/ ០២០២/០៥១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **តាំង ចាវទុង** ( TANG CHAO-TUNG ) សញ្ជាតិដើមចិន កើតថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៤៦ នៅកោះតៃវ៉ាន់ ប្រទេសចិន ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ៕

ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ : ៥៧ ច.ល

*ធ្វើនៅព្រះបរមរាជវាំង.រាជធានីភ្នំពេញ. ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០២*

ពរស-០២-០២-០០៦១

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈឹម តាន់

នស/រកត/ ០២០២/០៥២

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជាធិរាជ ខត្តិយោត្តមវង្ស វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **ចាង ម៉ៅ** ( CHANG MIAO ) សញ្ជាតិដើមចិន កើតថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៥៩ នៅកោះតៃវ៉ាន់ ប្រទេសចិន ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

ធ្វើនៅព្រះបរមរាជវាំង.រាជធានីភ្នំពេញ. ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០០២

៣៧ល.០២.០២.០០៦២

លេខ : ៥៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

[signature]

សៅ តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០២០២/០៥៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងសមាសភាពគណៈកម្មការកំណត់អាសនៈរដ្ឋសភា សម្រាប់នីតិកាលទី ៣ ដែលមានដូចខាងក្រោម :

| | |
|---|---|
| ១- ឯកឧត្តម **ឯក សំអុល** | ប្រធាន |
| ២- ឯកឧត្តម **ឃ្លោក ប៊ុនឌី** | អនុប្រធាន |
| ៣- ឯកឧត្តម **ខៃ ឆាយលាង** | សមាជិក |
| ៤- ឯកឧត្តម **អ៊ិច សារូ** | សមាជិក |
| ៥- ឯកឧត្តម **គីម ចំនួនសុមិត្រ** | សមាជិក |
| ៦- ឯកឧត្តម **សន ស៊ីថន** | សមាជិក |

មាត្រា ២ : គណៈកម្មការនេះ ត្រូវអនុវត្តការងារ និងភារកិច្ច ដូចមានចែងក្នុងសេចក្ដីសម្រេចលេខ ៥៣ សសរ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០១ របស់រាជរដ្ឋាភិបាល ស្ដីពីការបង្កើតគណៈកម្មការកំណត់អាសនៈរដ្ឋសភាសម្រាប់នីតិកាលទី ៣ ។

មាត្រា ៣ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ៕

ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ

**នរោត្តម សីហនុ**

លេខ : ៥៦ ច.ល

ធ្វើនៅព្រះបរមរាជវាំង,រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០២

៣រល-០២.០២-០០៦៤

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ០៤ ខែ ៣ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាអ៊ឹម តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៣០២/០៥៧

យើង

ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោក ម៉ត់ ពិត្សូ

ជា

ឧកញ៉ា

ព្រះហស្ដលេខា និង ព្រះរាជលញ្ឆករ

**នរោត្ដម សីហនុ**

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០២

ពរល.០២.០៣.០០៦៧

លេខ : ៧០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ០៧ ខែ ០៣ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] គាន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/០៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក,ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ២៥,០០០ លានរៀល ( ម្ភៃប្រាំពាន់លានរៀលគត់ ) ពីជំពូក ៤០ ( ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៤០ ( ចំណាយផ្សេងៗ ) របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយបង្វិលសង VAT ក្នុងឆ្នាំ ២០០២ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០២

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីគោរពជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឆន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ១៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ឆ្នាំង

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០១ គ្រឿង ជូនអង្គការន័រវេស្សសង្គ្រោះកុមារកម្ពុជា ( SCN ) ដែលបានជួយសាងសង់អគារសិក្សា ០៦ ខ្នង មាន ២២ បន្ទប់ : នៅក្នុងស្រុកទឹកផុស ចំនួន ០១ ខ្នង មាន ០៥ បន្ទប់ ស្រុកកំពង់ឆ្នាំង ចំនួន ០២ ខ្នង មាន ០៦ បន្ទប់ និង នៅស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំងចំនួន ០៣ ខ្នង មាន ១១ បន្ទប់ ចំណាយអស់ទឹកប្រាក់សរុបចំនួន ៥២.៣៧៧ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

### ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនតំណាងភាគីជប៉ុន ចំនួន ០៥ រូប ដែលមានស្នាដៃល្អក្នុងការផ្តល់ជំនួយសំរាប់គំរោងស្តារ និងបង្កើនសមត្ថភាពផ្គត់ផ្គង់អគ្គិសនី នៅជុំវិញរាជធានីភ្នំពេញ ដែលមានតម្លៃជាទឹកប្រាក់ចំនួន ៣.៣៨៣.០០០.០០០ យ៉េន ដូចមានរាយនាមខាងក្រោមនេះ ÷

១-ឯកឧត្តម **GOTARO OGAWA** ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
២-លោក **NORIO MATSUDA , JICA**
៣-លោក **MIZOBE , NIPPONKOEI**
៤-លោក **NOBUHIDE KURIHARA , KURIHARA**
៥-លោក **KAZUO NOZAKI , ITOCHU**

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ**...១០៨...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

&&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## ស ំ រ េ ច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយសំរិទ្ធការងារ** ជូនមន្ត្រីរាជការចំនួន ០២ រូប នៃមន្ទីរធម្មការ និងសាសនារាជធានីភ្នំពេញ ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ក្នុងឆ្នាំ ២០០១ ដូចមានរាយនាមខាងក្រោមនេះ ÷

១ - លោក **ឃាញ់ ចំរើន** មន្ត្រីនៃមន្ទីរធម្មការ និង សាសនា

២ - លោក **គិន សារឿន** មន្ត្រីនៃមន្ទីរធម្មការ និង សាសនា

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...១០៩...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

&&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## ស ម្រេ ច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ប្រគេនមន្ត្រីសង្ឃ ១០ អង្គ ដែលមានគុណូបការៈដ៏ថ្លៃថ្លា ក្នុងការពង្រីងវិស័យព្រះពុទ្ធសាសនាដូចមានរាយព្រះនាមខាងក្រោមនេះ ÷

ក- **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** :

១-ព្រះភិក្ខុ **សែម សារិន** ព្រះបាឡាត់គណរាជធានីភ្នំពេញ

២-ព្រះមុនីសោភ័ណ **រ័ត្ន សារឿន** រាជាគណៈថ្នាក់កិត្តិយស ទីប្រឹក្សាសម្តេចព្រះសង្ឃរាជគណៈមហានិកាយ និង ជាព្រះចៅអធិការវត្តសំរោងអណ្តែត

ខ-**មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** :

១-ព្រះភិក្ខុ **យក់ កុយ** ព្រះធម្មធរអនុគណខ័ណ្ឌដូនពេញ និង ជាគ្រូសូធ្យស្តាំវត្តកោះ

២-ព្រះភិក្ខុ **គាន សុធានណារិទ្ធ** ព្រះចៅអធិការវត្តព្រែកប្រា

៣-ព្រះភិក្ខុ **សៅ មុនី** ព្រះចៅអធិការវត្តកំសាន្ត

៤-ព្រះភិក្ខុ **ចាន់ កុសល** ព្រះចៅអធិការវត្តប្រជុំសាគរ

**គ-មេជាយមុនីសារាគំណន** ថ្នាក់ **អស្សប្រុទ្ធិ** :

១- ព្រះភិក្ខុ **សែម សុគា** ព្រះចៅអធិការវត្តពូនភ្នំ

២- ព្រះភិក្ខុ **ឈឹម គេត** ព្រះចៅអធិការវត្តពោធិព្រះបាត្រ

៣- ព្រះភិក្ខុ **ចាន់ ស៊ី** អនុប្រធានសមាគមពុទ្ធិកសិក្សាទូទាំងប្រទេស

៤ - ព្រះភិក្ខុ **ទឹម សម្បត្តិ** ព្រះចៅអធិការវត្តញាណរង្សី

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១១០ អនក្រ.តត.

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៦ / អនក្រ . បក / ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមតម្រូវការចាំបាច់ការងាររបស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១** : តែងតាំងលោក **ស្នួន សុផល** ជាជំនួយការលោកជំទាវ គេត ថុល ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ចម្លងជូន :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ- កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១១១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០២ រូប ដែលបានជួយឧបត្ថម្ភថវិកាចំនួន ២៨.០៤០ ដុល្លារអាមេរិក ក្នុងការកសាងវត្តប្រាសាទភាស ឃុំសំរង្គ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម ÷

១-លោក **ពេជ្រ សារឿន**

២-លោក **ពេជ្រ ចាន់** ហៅ **សារ៉ន**

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និង អភិបាលខេត្តបន្ទាយ-មានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១១២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តបន្ទាយមានជ័យ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០២ រូប ដែលបានជួយជួសជុលផ្លូវលំប្រវែង ៣.៨៥០ ម៉ែត្រ កសាងផ្លូវលំថ្មីប្រវែង ២.៦៣៨ ម៉ែត្រ ក្លោងទ្វារសាលារៀនចំនួន ០៣ កន្លែង សាលាឃុំ ០១ ខ្នង និងដាក់លូបង្ហូរទឹកចំនួន ១០៦ កង់ នៅក្នុងឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម ÷

១-លោក **សាន ស៊ានឃួរ** ថវិកាចំនួន ២៥.៦១២ ដុល្លារអាមេរិក

២-លោក **សៀង អ៊ិច** ថវិកាចំនួន ១០.០០០ ដុល្លារអាមេរិក

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/ ៚

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១១៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

❧❧❧❧❧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **សេនា** ជាកិច្ចបច្ឆាមរណៈជូនសព ឯកឧត្តម **យិន ចន** អគ្គលេខាធិការរងក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ដែលមានស្នាដៃល្អ និង គុណបំណាច់ខ្ពង់ខ្ពស់ក្នុងការបំរើជាតិមាតុភូមិ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ... ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ១១៨ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ចាយ ស៊ាងអ៊ី** ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយស្តារ និង កសាងសមិទ្ធផលសាធារណៈនានា ក្នុងខេត្តកំពង់ចាម ដូចជា សាលារៀន ព្រះវិហារ ផ្លូវលំ ស្រះទឹក សាលាធម្មសភា របង ។ល។ ចំណាយអស់ទឹកប្រាក់សរុប ចំនួន ១៥៣.៥០០ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១១៥ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

*****

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សំរេច

**មាត្រា ១ :** ត្រូវបានតែងតាំងមន្ត្រីរាជការ នៃក្រសួងផែនការ ដូចមានរាយនាមខាងក្រោម :

- លោកស្រី **ចាន់ លីណា** ជានាយករង នៃវិទ្យាស្ថានជាតិស្ថិតិ
- លោក **ខៀវ សារី** ជានាយករង នៃវិទ្យាស្ថានជាតិស្ថិតិ
- លោក **នុត ចន្ទសុខា** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានផែនការ

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ឱ្យបានសំរេច ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១១៦ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានតែងតាំងមន្ត្រីថ្នាក់ប្រធាននាយកដ្ឋានចំនួន ០២រូប នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចមានរាយនាមខាងក្រោម ÷

១-លោក **កៅ ឌុំចាន្ធ** ជាប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម

២-លោក **ដាត់ លេខ** ជាប្រធាននាយកដ្ឋានកសិ-ឧស្សាហកម្ម

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធនិងសាម៉ីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី០៧ ខែមីនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៥ សសរ

## សេចក្តីសំរេច

## ស្តីពីការផ្ទេរសិទ្ធ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្រលេខ នស / រកត ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំ រេ ច

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធជូនឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជារដ្ឋមន្ត្រីស្តីទីក្រសួងពាណិជ្ជកម្ម ជំនួសឯកឧត្តម **ចម ប្រសិទ្ធ** ដែលត្រូវអញ្ជើញទៅ បំពេញបេសកកម្មនៅបរទេស ចាប់ពីថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០២ រហូតដល់ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០២ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និង ឯកឧត្តម **ស៊ុយ សែម** ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ២ ( ដើម្បីអនុវត្ត )
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៦ សសរ

# សេចក្តីសំរេច

## ស្តីពីការបង្កើតគណៈកម្មការទទួលបន្ទុករៀបចំសន្និសីទកំពូលពុទ្ធសាសនាពិភពលោកលើកទី ៣ ថ្ងៃទី ០៥-០៩ ខែ ធ្នូ ឆ្នាំ ២០០២ នៅរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញ ព្រះរាជក្រឹត្យលេខ នស-រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញ ព្រះរាជក្រឹត្យលេខ ០២-នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី .
- បានឃើញ កិច្ចព្រមព្រៀងរវាងអង្គការពុទ្ធសាសនាជប៉ុន និងពុទ្ធសាសនាកម្ពុជា ស្តីពីការរៀបចំសន្និសីទកំពូលពុទ្ធសាសនាពិភពលោកលើកទី ៣ ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០១
- បានឃើញ សំណូមពររបស់សម្តេចព្រះសង្ឃរាជ ទេព វង្ស គណៈមហានិកាយ នាសម័យប្រជុំនៅវត្តឧណ្ណាលោម កាលពីថ្ងៃទី ០៦-០៩-២០០១ .
- យោងតាមសំណូមពរ និងតម្រូវការចាំបាច់ .

## សំរេច

ប្រការ ១ : បង្កើតគណៈកម្មការមួយ ទទួលបន្ទុករៀបចំសន្និសីទកំពូលពុទ្ធសាសនាពិភពលោកលើកទី ៣ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី ០៥ ដល់ ០៩ ខែធ្នូ ឆ្នាំ ២០០២ នៅរាជធានីភ្នំពេញ ដែលមានសមាសភាព ដូចខាងក្រោម :

១- ឯកឧត្តម អ្នកឧកញ៉ាចៅហ្វាវាំង **គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង និងជាប្រធានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ — ប្រធាន

២- សម្តេចព្រះពោធិវង្ស នន់ ងែត — ព្រះអធិការពុទ្ធិកសិក្សា និងព្រះមេគណរាជធានីភ្នំពេញ — អនុប្រធាន

៣- ឯកឧត្តម ជា សាវឿន — រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា — អនុប្រធាន

៤- ឯកឧត្តម មិន ឃិន — អគ្គលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មការរៀបចំបុណ្យជាតិ-អន្តរជាតិ — អនុប្រធានអចិន្ត្រៃយ៍

៥- ព្រះវិន័យសំវរ **ឈួន វ៉ា** នាយកប្រតិបត្តិអភិបាលកិច្ចសង្ឃទូទាំងប្រទេស សមាជិក
៦- ព្រះសុធម្មកោសល **ជា សំអាន** ព្រះបាឡាត់វេទីវង្សា សាលាគណខេត្តកណ្តាល សមាជិក
៧- ព្រះអរិយមុនី **លឹម សុវណ្ណ** នាយករងពុទ្ធិកវិទ្យាល័យសម្តេច បួរ គ្រី សមាជិក
៨- ឯកឧត្តម **ឈន អឿម** រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា សមាជិក
៩- ឯកឧត្តម **អ៊ិន ទីសារអ៊ិម** រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា សមាជិក
១០- ឯកឧត្តម **អ៊ុជ គឹមអន** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក
១១- ឯកឧត្តម **ថោង ខុន** រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក
១២- ឯកឧត្តម ឧត្តមសេនីយ៍ឯក **នេត សាវឿន** អគ្គស្នងការរងនគរបាលជាតិក្រសួងមហាផ្ទៃ សមាជិក
១៣- ឯកឧត្តម **ម៉ុន សំ** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
១៤- ឯកឧត្តម **ថាច់ ផែន** អនុរដ្ឋលេខាធិការក្រសួងពត៌មាន សមាជិក
១៥- ឯកឧត្តម **កែវ សាផល** អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលកម្ពុជា សមាជិក
១៦- ឯកឧត្តម **អ៊ុក ចាន់** អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
១៧- ឯកឧត្តម **ចាប ញ៉ុលឹម៉ុង** អភិបាលខេត្តសៀមរាប សមាជិក
១៨- ឯកឧត្តម **ម៉ម់ សារិន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរងរាជធានីភ្នំពេញ សមាជិក
១៩- ឯកឧត្តម **ជា សុខុម** អគ្គលេខាធិការរងនៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ សមាជិក
២០- ឯកឧត្តម **ជា គាន** អគ្គលេខាធិការរងនៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ សមាជិក
២១- ឯកឧត្តម **វ៉ាន់ ទារ៉ា** អគ្គលេខាធិការរងនៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ សមាជិក
២២- ឯកឧត្តម **នេត វិហារ** អគ្គនាយករងអាជ្ញាធរអប្សរា សមាជិក
២៣- ឯកឧត្តម **ហាឡឹ សុត** អគ្គនាយកនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
២៤- ឯកឧត្តម **វ៉ែត ឝុយសិរាន** អគ្គនាយកនៃក្រសួងសុខាភិបាល សមាជិក
២៥- លោក **ប៊ូន លឹមះហាង** ប្រធាននាយកដ្ឋានផ្គត់ផ្គង់ ហិរញ្ញកិច្ចនៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច :

- ទទួលបន្ទុករៀបចំសន្និសីទកំពូលពុទ្ធសាសនាពិភពលោក លើកទី ៣ ឱ្យប្រព្រឹត្តទៅទទួលបានលទ្ធផលល្អប្រសើរ ស្របតាមគោលបំណង និងសំណូមពរនៃកិច្ចព្រមព្រៀង
- **រៀបចំពិធីបដិសណ្ឋារកិច្ច និងពិធីការឱ្យបានសម** ស្របល្អ ក្នុងកម្រិតសន្និសីទថ្នាក់អន្តរជាតិ
- **រៀបចំការពារសន្តិសុខ របៀបរៀបរយ សណ្តាប់**ធ្នាប់សង្គម ចរាចរដល់គណៈប្រតិភូ និងសមាជិកអង្គសន្និសីទ ឱ្យបានគង់នូវសុវត្ថិភាពគ្រប់ទីកន្លែង
- អញ្ជើញថ្នាក់ដឹកនាំជាតិ និងភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ពាក់ព័ន្ធចូលរួមតាមចំនួនកំណត់ជាក់ស្តែង
- ទទួលបន្ទុកសហការរៀបចំខ្លឹមសារ ឯកសារពាក់ព័ន្ធ និងបកប្រែភាសាបំរើការរៀបចំសន្និសីទទាំងមូល តាមកម្មវិធីកំណត់
- សហការសម្របសម្រួលប្រព័ន្ធឃោសនាជាតិ និងអន្តរជាតិ ដើម្បីបង្កលក្ខណៈធ្វើការផ្សព្វផ្សាយអំពីខ្លឹមសារសន្និសីទឱ្យបានទូលំទូលាយ

- ទំនាក់ទំនងល្អ ជិតស្និទ្ធជាមួយសម្តេចព្រះសង្ឃរាជទាំងពីរគណៈ មន្ត្រីសង្ឃជំនាញ និងភាគីជប៉ុន ដើម្បីធ្វើឱ្យសន្និសីទសំរេចលទ្ធផលល្អ
- សហការដោះស្រាយទីតាំងសម្រាប់សន្និសីទកន្លែងស្នាក់អាស្រ័យ ចង្ហាន់ ម្ហូបអាហារ ភេសជ្ជៈ រថយន្ត ផ្លាកសញ្ញាផ្សេងៗ ចាំបាច់ និងផ្នែកសុខាភិបាល
- ត្រៀមលក្ខណៈឱ្យបានល្អ បំរើដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនៅខេត្តសៀមរាប និងនៅទីកន្លែងផ្សេងៗទៀត តាមកម្មវិធីកំណត់ជាក់ស្តែង

ប្រការ ៣ : ក្នុងការបំពេញភារកិច្ចរបស់ខ្លួន បំរើវេទិកាសន្និសីទកំពូលនេះ ក្រៅពីថវិកាដែលមានក្នុងគម្រោង តាមស្មារតីនៃកិច្ចព្រមព្រៀងរវាងភាគីទាំងពីរ គណៈកម្មការនេះ អាចលើកគម្រោងសំរាប់បំពេញបន្ថែមទៅលើចំណាយដែលខ្វះ ស្នើសុំយោបល់សំរេចពីទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីមានលទ្ធភាពដោះស្រាយទាន់ពេលវេលា ។

ប្រការ ៤ : គណៈកម្មការនេះ ត្រូវមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយជាសេនាធិការ ដែលមានទីតាំងនៅអគ្គលេខាធិការដ្ឋានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ និងប្រើប្រាស់ត្រារបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ក្នុងរាល់ការងារទំនាក់ទំនងរដ្ឋបាល ។

ប្រការ ៥ : គណៈកម្មការនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញមួយចំនួនផ្សេងៗទៀត តាមសំណូមពរ និងតម្រូវការចាំបាច់នៃការងារ ។

ប្រការ ៦ : ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង, រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា, គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ, រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, រដ្ឋមន្ត្រីក្រសួងព័ត៌មាន, រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលកម្ពុជា, សាលាក្រុងភ្នំពេញ និងឯកឧត្តម អស់លោក ដូចមានរាយនាមក្នុងប្រការមួយ ត្រូវទទួលភារកិច្ចអនុវត្តសេចក្តីសម្រេចនេះឱ្យសម្រេចលទ្ធផលល្អ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០២

ហ៊ុន សែន

ចម្លងប្រគេន-ជូន :
- សម្តេចព្រះសង្ឃរាជទាំងពីរគណៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

"ដើម្បីប្រគេន-ជូនជ្រាប"
- ដូចក្នុងប្រការ ៦

"ដើម្បីសហការអនុវត្ត"
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៧ សសរ

# សេចក្ដីសំរេច
## ស្ដីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្ដម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្ដីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅធ្វើទស្សនកិច្ចនៅសឹង្ហបុរី ដើម្បីថ្លែងបឋកថាអាស៊ាន នៅសាកលវិទ្យាល័យជាតិសឹង្ហបុរី ចាប់ពីថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០២ រហូតដល់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្ដម ស ខេង ត្រូវអនុវត្តសេចក្ដីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ចម្លងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៧ . សរាចរ

# សារាចរណែនាំ

## ស្តីពីការរៀបចំបុណ្យចូលឆ្នាំថ្មី ឆ្នាំមមី ចត្វាស័ក ព.ស ២៥៤៦ គ.ស ២០០២

*****

ជារៀងរាល់ឆ្នាំ ប្រជាពលរដ្ឋខ្មែរគ្រប់រូបទូទាំងប្រទេស ទាំងនៅទីក្រុង ទាំងនៅជនបទ និងទាំងបងប្អូនប្រជាពលរដ្ឋកម្ពុជាដែលរស់នៅប្រទេសក្រៅ តែងតែប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មី ជាប្រពៃណីជាតិរបស់ខ្លួន ក្នុងមនោសញ្ចេតនាសប្បាយរីករាយ ប្រកបដោយភក្តីភាព និងសាមគ្គីភាពក្រៃលែង ។

ពិធីនេះ ប្រារព្ធឡើងដើម្បីសំដែងនូវអំណរសាទរស្វាគមន៍ចំពោះការចូលមកដល់នៃឆ្នាំថ្មី និងសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ថ្វាយព្រះពរចំពោះព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង និងសម្តេចព្រះរាជអគ្គមហេសី ជាទីសក្ការៈ ថ្វាយព្រះពរ ជូនពរថ្នាក់ដឹកនាំសមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល មន្ត្រីរាជការ បុគ្គលិក កម្មករ និយោជិត និងបុព្វការីទាំងឡាយ មានមាតាបិតាជាដើម សំដៅបង្កើនឡើងនូវមនោសញ្ចេតនាគោរព ស្រឡាញ់ជាភាតរភាព សាមគ្គីភាព ស្និទ្ធស្នាល ទទួលពរសព្ទសាធុការពីទេវតាឆ្នាំថ្មី តាមប្រពៃណីជាតិ ក្រោយពីបានបញ្ចប់នូវការងារប្រមូលភោគផលកសិផល និងអនុផលផ្សេងៗនាឆ្នាំចាស់ និងមុនការចាប់ផ្តើមបង្កបង្កើនផលក្នុងឆ្នាំថ្មីដែលនឹងត្រូវដំណើរការ នៅរដូវវស្សាខាងមុខបន្តទៀត ។

ឆ្នាំនេះ ពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំមមី ចត្វាស័ក ព.ស ២៥៤៦ គ.ស ២០០២ នឹងត្រូវប្រព្រឹត្តទៅក្នុងរយៈពេល ៣ថ្ងៃគឺ:

- ថ្ងៃអាទិត្យ ៣ កើត ខែពិសាខ ត្រូវនឹងថ្ងៃទី ១៤ ខែមេសា ឆ្នាំ២០០២ វេលាម៉ោង ០៦ ព្រឹក ជាថ្ងៃចូលឆ្នាំ ។
- ថ្ងៃច័ន្ទ ៤ កើត ខែ ពិសាខ ត្រូវនឹងថ្ងៃទី ១៥ ខែ មេសា គ.ស ២០០២ ជាវារៈវនបត ។
- ថ្ងៃអង្គារ ៥ កើត ខែ ពិសាខ ត្រូវនឹងថ្ងៃទី ១៦ ខែ មេសា គ.ស ២០០២ ជាវារៈឡើងស័ក នៅវេលាម៉ោង ០៩:៣៧ នាទី និង ៤៨ វិនាទី គម្រប់ជាសង្ក្រាន្តបីថ្ងៃ ដោយបរិបូណ៌ និងចូលឆ្នាំ មមី ចត្វាស័ក តរៀងទៅ ។

ដើម្បីបង្កភាពសប្បាយរីករាយ និង រក្សាប្រពៃណីទំនៀមទម្លាប់របស់ជាតិឱ្យបានគង់វង្ស និង ភាពរុងរឿងនោះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដាក់ចេញនូវសារាចរណែនាំដូចខាងក្រោម :

១-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន អង្គភាព រាជធានីភ្នំពេញ និងខេត្ត-ក្រុង វត្តអារាម សាលារៀន រោងចក្រ សហគ្រាស និងគ្រប់គេហដ្ឋាន ត្រូវរៀបចំសំអាត តុបតែងលំអ រំលេចដោយបដា ពាក្យស្លោក ទង់ជាតិ ទង់ជ្វាលា និងរៀបចំគ្រឿងសក្ការបូជា មានផ្កាភ្ញី ទៀនធូបជាដើម ថ្វាយព្រះរតនត្រ័យ និងរៀបចំពលីការដ៏សមរម្យ មាននំចំណីផ្លែឈើជាដើម ទទួលទេវតាឆ្នាំថ្មី ព្រមទាំងត្រូវតុបតែងលំអដោយភ្លើងពណ៌អគ្គិសនី និងនៅតាមជនបទចាត់តាំងឱ្យមានការដុតគោមប្រទីបជ្វាលា ឱ្យបានភ្លឺព្រោងព្រាតនាពេលយប់ ក្នុងរយៈពេលបីថ្ងៃនៃការចូលឆ្នាំថ្មីប្រពៃណីជាតិ ។

២-ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវមានផែនការណែនាំជាក់ស្តែងដល់អង្គភាពក្រោមឱវាទ និងគ្រប់ខេត្ត-ក្រុង បង្កើនកិច្ចការពារថែរក្សាធានាសន្តិសុខ របៀបរៀបរយសណ្តាប់ធ្នាប់សង្គម បង្កបានភាពសប្បាយរីករាយ ធានាសុវត្ថិភាពជូនមហាជន ប្រជាជន មុន-ក្រោយ និងក្នុងពេលប្រារព្ធពិធីបុណ្យប្រពៃណីជាតិនេះ ។

៣-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវណែនាំដល់បណ្តាមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង ចាត់តាំងសំដែងសិល្បៈ និងទស្សនីយភាព ជូនប្រជារាស្ត្រទស្សនាកំសាន្ត តាមទីសាធារណៈ និងបំផុសចលនាប្រជាពលរដ្ឋចូលរួមឱ្យបានផុសផុលក្នុង ការចាត់តាំងលេងល្បែងប្រជាប្រិយរបស់ជាតិ ដូចជា ចោលឈូង បោះអង្គុញ ទាញព្រ័ត្រ ទាត់សី លាក់កន្សែង រាំកំសាន្ត សប្បាយ តាមរមណីយដ្ឋានប្រវត្តិសាស្ត្រនានា តាមវត្តអារាម ទីប្រជុំជន ភូមិ ឃុំ តាមទម្លាប់នៃតំបន់នីមួយៗ ដើម្បីអប់រំ និងបង្ហាញឱ្យយុវជនជំនាន់ក្រោយបានយល់ដឹង និងឃើញច្បាស់ ហើយបន្តវេនថែរក្សាឱ្យបានគង់វង្ស ។ រាល់ល្បែងទាំងឡាយ ដែលនាំឱ្យខាតបង់ អន្តរាយទ្រព្យសម្បត្តិ និងនាំឱ្យមានគ្រោះថ្នាក់ប៉ះពាល់ដល់កេរ្តិ៍យស ផ្ទុយពីប្រពៃណីថ្លៃថ្នូររបស់ជាតិ ដូចជាល្បែងស៊ីសង ល្បែងភ្នាល់ផ្សេងៗ ល្បែងជះទឹកមានពណ៌ ទឹកកខ្វក់ គប់ស្បោងទឹក លាបធ្យូង បាចម្សៅ ទះគក់ដោយដៃ វាយដោយរំពាត់ ដល់អ្នក ដំណើរដែលស្លៀកសំលៀកបំពាក់ដ៏មានតម្លៃ ត្រូវហាមឃាត់ដាច់ខាត ។

៤-ក្រសួងព័ត៌មាន ត្រូវចាត់តាំងបណ្តាញវិទ្យុ ទូរទស្សន៍ជាតិ និងឯកជន ចុះធ្វើសកម្មភាពយកព័ត៌មាន ផ្សព្វផ្សាយសកម្មភាព ទិដ្ឋភាពជាក់ស្តែងនៃថ្ងៃបុណ្យ ទាំងពិធីសាសនា និងប្រពៃណីជាតិ ដូចជាសកម្មភាពល្បែងប្រជាប្រិយ គ្រប់ប្រភេទតាមតំបន់នីមួយៗ ហើយផ្សព្វផ្សាយឱ្យបានទូលំទូលាយ ។

៥-ក្រសួងធម្មការ និងសាសនា សហការជាមួយអាជ្ញាធរខេត្ត-ក្រុង ត្រូវណែនាំដល់អង្គភាពក្រោមឱវាទ រៀបចំពិធីសាសនា តាមវត្តអារាមនីមួយៗឱ្យបានសមស្របតាមប្រពៃណីសាសនា ប្រពៃណីជាតិ ប្រកបដោយបរិយាកាសរីករាយ ដូចជាពិធីពូនភ្នំខ្សាច់ សម្អាតបរិវេណក្នុងវត្ត សម្អាតព្រះពុទ្ធបដិមា ពិធីស្រង់ទឹកព្រះសង្ឃ ស្រង់ទឹកសីលវន្ត សីលវតី មាតាបិតា ចាស់ព្រឹទ្ធាចារ្យ ជាដើម ។ ត្រូវយកចិត្តទុកដាក់ អំពាវនាវពុទ្ធបរិស័ទឱ្យចាត់តាំងប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលជូនដល់បដិសន្ធិវិញ្ញាណរបស់បងប្អូនជនរួមជាតិ ដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបប្រល័យពូជសាសន៍ប៉ុលពត នៅតាមបូជនីយដ្ឋាន តាមស្តូប តាមវត្តអារាមដែលបានតម្កល់អដ្ឋិធាតុរបស់អ្នកទាំងនោះ ។

៦-គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ត្រូវមានផែនការណែនាំលំអិត សម្រាប់អនុវត្តជាក់ស្តែង និងត្រូវរៀបចំកម្មវិធីណែនាំដល់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន អង្គភាព ខេត្ត-ក្រុង និងសមាគម អង្គការក្រៅរដ្ឋាភិបាលនានា ចាត់តាំងគណៈប្រតិភូ និងបំផុសអំពាវនាវសប្បុរសជន ឱ្យជួយឧបត្ថម្ភអំណោយសម្ភារៈ ថវិកា ចុះសួរសុខទុក្ខអ្នកមានជម្ងឺរបួស កំពុងសំរាកព្យាបាលនៅតាមមន្ទីរពេទ្យនានា និងអ្នកពិការ កុមារកំព្រានៅតាមមណ្ឌលនានា និងចាស់ព្រឹទ្ធាចារ្យឥតទីពឹង ដើម្បីជាការលើកទឹកចិត្ត និងបង្កើនស្មារតីជួយគ្នាទៅវិញទៅមក ក្នុងគ្រាមានទុក្ខលំបាក ក៏ដូចជាក្នុងឱកាសសប្បាយរីករាយ ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សង្ឃឹមថា គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន គ្រប់ស្ថាប័ន អង្គភាព ខេត្ត-ក្រុង ទូទាំងប្រទេស នឹងអនុវត្តតាមស្មារតីនៃសារាចរណែនាំនេះ សំរេចបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមីនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន និងខេត្ត-ក្រុង
"ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ពា ក្យ ស្លោ ក

## សំរាប់ប្រើប្រាស់ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំមមី
## ចន្ទាស័ក ព.ស ២៥៤៦ គ.ស ២០០២

១- សួស្តី ឆ្នាំថ្មី !

២- សូមជូនពរឆ្នាំថ្មី ឆ្នាំមមី សិរីសួស្តីជ័យមង្គល និងវិបុលសុខគ្រប់ប្រការ

៣- សូមប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខ បវរមហាប្រសើរ ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំមមី

៤- ឆ្នាំថ្មី ភារកិច្ចថ្មី ជ័យជំនះថ្មី !

៥- សូមថ្វាយព្រះពរ សម្តេចឪ សម្តេចម៉ែ សូមមានព្រះជន្មាយុយឺនយូរ

៦- ជយោ ! សាមគ្គីព្រះបិតាបង្រួបបង្រួម និងផ្សះផ្សាជាតិ

៧- ជយោ ! ព្រះរាជាណាចក្រកម្ពុជា

៨- ជាតិ សាសនា ព្រះមហាក្សត្រ

៩- ជយោ ! សន្តិភាព និងការអភិវឌ្ឍន៍

១០- ជយោ ! រាជរដ្ឋាភិបាលសេដ្ឋកិច្ច

១១- សន្សំសំចៃ គឺស្នេហាជាតិ

១២- ស្វាគមន៍ ឆ្នាំ ២០០២ ឆ្នាំអនុវត្តគោលការណ៍វិមជ្ឈការឃុំ-សង្កាត់

១៣- ជយោ ! ឆ្នាំ ២០០២ ឆ្នាំពង្រឹងគ្រឹះលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧១១ សហវ.......

ភ្នំពេញ,ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០២

## ប្រកាសអន្តរក្រសួង

## ស្តីពី

## ការបង្កើតរង្វាន់ទេយ្យបុរេប្រទាន

## នៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា លេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២/.នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤។

-បានឃើញច្បាប់ស្តីពី ប្រពន្ធ័ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១.នស.ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១.នស/៩៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះ រាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ។

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថៃទី ៣១ ខែធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការ គ្រប់គ្រងឆ្នាំ ២០០២ ។

-បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ/បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញត្តទូទៅ នៃគណនេយ្យសាធារណៈ ។

-បានឃើញប្រកាសលេខ ០០៤ សហវ/មប្រក ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញត្តទូទៅ នៃគណនេយ្យសាធារណៈ ។

-បានឃើញលិខិតលេខ ១១៥/សហវ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញត្តទូទៅ នៃគណនេយ្យសាធារណៈ ។

-បានឃើញសារាចរណែនាំលេខ ០០៣ សហវ.ម ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីរង្វាន់ទេយ្យបុរេប្រទាន ។

-បានឃើញប្រកាសលេខ ១២៩ ប្រក/សហវ ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៩៧ ស្តីពីការកំណត់ទឹកប្រាក់រង្វាន់ទេយ្យបុរេប្រទាន ជំពូក១១ សំរាប់ទូទាត់ចំណាយចាំបាច់ទៅលើដំណើរការ រដ្ឋបាល សំភារៈ និង ការជួសជុលតូច ។

-បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បច្ចុប្បន្ន ។

## សំរេច

**ប្រការ១** : ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក១១ ទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ដើម្បីទូទាត់ចំណាយទាំងឡាយណាដែលមានចែងក្នុងមាត្រា ៦៤ នៃអនុក្រឹត្យលេខ ៨២អនក្រ/បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ ។ ចំនួនទឹកប្រាក់ជាអតិបរមា នៃចំណាយដែលអនុញ្ញាតអោយ រជ្ជទេយ្យករបុរេប្រទានធ្វើការទូទាត់ត្រូវកំណត់ក្រោម ៥០០.០០០រ០០( ប្រាំរយពាន់រៀលគត់ ) តាមចំណោតថ្នាក់ចំណាយនិមួយ១ ដូចមានចែងក្នុងតារាង ឧបសម្ព័ន្ធភ្ជាប់ជ.មួយនូវប្រកាសអន្តរក្រសួង ។

**ប្រការ ២** : ចំនួនទឹកប្រាក់នៃរជ្ជទេយ្យបុរេប្រទានជំពូក១១សំរាប់មួយជុំនៃឆ្នាំត្រូវបានកំណត់ត្រឹមចំនួន ៧៦.០០០.០០០រ០០ (ចិតសិបប្រាំមួយលានរៀលគត់) ។

**ប្រការ ៣** : សេចក្តីសំរេចទាំងឡាយដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤** : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាន ព្រមទាំងប្រធាន គ្រប់អង្គភាពពាក់ពន្ធ័ទាំងអស់ក្រោមឱវាទក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និងយុវនីតិសម្បទា មានភារកិច្ចទទួលបន្ទុកអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/

រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

**អ៊ិត សំហេង**

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**គាត ឈន់**

**កន្លែងទទួល**

-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-ដូចប្រការបួន ដើម្បីមុខការ
-ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ២២៤ សហវ.

# ប្រកាស

## ស្តីពី

## ការបង្កើតផ្នែកគ្រប់គ្រង និង ប្រមូលពន្ធតាមរបបពិត

************

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ៧៦៥សហវ.ពដ.ចុះថ្ងៃទី១២ ខែតុលាឆ្នាំ២០០១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការបង្កើតអង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធធំ និង អង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធមធ្យម
- បានឃើញ តម្រូវការនៃការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមលិខិតស្នើរបស់ប្រធាននាយកដ្ឋានពន្ធដារ

## សម្រេច:

**ប្រការ១:** ត្រូវបានបង្កើតផ្នែកគ្រប់គ្រង និង ប្រមូលពន្ធតាមរបបពិតនៅក្នុងសាខាពន្ធដារខេត្តបន្ទាយមានជ័យ-កំពង់ស្ពឺ-កំពង់ឆ្នាំង-កណ្តាល និង ស្វាយរៀង ដើម្បីគ្រប់គ្រង និង ប្រមូលពន្ធចំពោះសហគ្រាស ក្រោមគ្រប់ទ្រង់ទ្រាយដែលត្រូវជាប់ពន្ធតាមរបបពិត ហើយមានទីស្នាក់ការជាគោលដើមនៅក្នុងខេត្តរបស់ខ្លួន ។

**ប្រការ២:** ផ្នែកគ្រប់គ្រង និង ប្រមូលពន្ធតាមរបបពិតដូចមានចែងក្នុងប្រការ១ខាងលើ រួមមាន៤ក្រុម:

- ក្រុមចុះបញ្ជី និង សេវាអ្នកជាប់ពន្ធ
- ក្រុមចាត់ចែងលិខិតប្រកាស និង ប្រមូលពន្ធ
- ក្រុមតឹងទារប្រាក់ពន្ធ
- ក្រុមសវនកម្មសារពើពន្ធ ។

**ប្រការ៣:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពន្ធដារ និង អង្គភាពដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០២

គាត ឈន់

**ចម្លងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សាលាខេត្ត ដែលពាក់ព័ន្ធ
  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៣
- អង្គភាពពន្ធដារ ដែលពាក់ព័ន្ធ
  " ដើម្បីអនុវត្ត "
- កាលប្បវត្តិ-ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ២២៥ សហវ

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០០២

**ប្រកាសអន្តរក្រសួង**

**ស្តីពី**

**ការបង្កើតវិជ្ជាធីយប្បុរេប្រទាន**
**នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ ន.ស.រ.ក.ត ១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២.នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩
- បានឃើញព្រះរាជក្រមលេខនស.រកម ១២០១/១៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០២
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក. ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ

- បានឃើញសារាចរណែនាំលេខ ០០៣ សហវ.ម ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្តីពីរជ្ជទេយ្យបុរេប្រទាន
- បានឃើញប្រកាសលេខ ១២៩ ប្រក.សហវ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៧ ស្តីពីការកំណត់ទឹកប្រាក់រជ្ជទេយ្យបុរេប្រទានជំពូក ១១ សំរាប់ទូទាត់ចំណាយចាំបាច់ទៅលើដំណើរការរដ្ឋបាលសំភារៈ និង ការជួសជុលតូច
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

## សំរេច

ប្រការ១ : ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក ១១ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីទូទាត់ចំណាយទាំងឡាយណាដែលមានចែកក្នុងមាត្រា ៦៤ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ។ ចំនួនទឹកប្រាក់ជាអតិបរិមា នៃចំណាយដែលអនុញ្ញាតអោយរជ្ជទេយ្យករបុរេប្រទានធ្វើការទូទាត់ត្រូវកំណត់កំរិតក្រោម ៥០០.០០០៛០០ ( ប្រាំរយពាន់រៀលគត់ ) តាមចំណាត់ថ្នាក់ចំណាយនីមួយ ៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសអន្តរក្រសួង ។

ប្រការ២ : ចំនួនទឹកប្រាក់នៃរជ្ជទេយ្យបុរេប្រទានជំពូក ១១ សំរាប់មួយជុំនៃឆ្នាំ ត្រូវបានកំណត់ត្រឹមចំនួន ២៤៤.៨២៥.០០០៛០០ ( ពីររយសែសិបបួនលានប្រាំបីរយម្ភៃប្រាំពាន់រៀលគត់ ) ។

ប្រការ៣ : សេចក្តីសំរេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ៤ : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋាន ព្រមទាំងប្រធានគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារៈកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប.ក. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
រដ្ឋលេខាធិការ
គង់ វិបុល

អគ្គលេខាធិការ
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
សុខ ចិន្តា

**កន្លែងទទួល**

- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
  *" ដើម្បីជូនជ្រាប "*
- *ដូចប្រការ ៤*
  *" ដើម្បីមុខការ "*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ២២៧ សហវ

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០២

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការតែងតាំងថ្នាក់ខាងបើកផ្តល់សំរាប់បើកប្រាក់បៀវត្ស និងប្រាក់អន្តរាគមន៍ ក្នុងវិស័យ សង្គមកិច្ច និង វប្បធម៌ ជូនមន្ត្រីរាជការនៅអាជ្ញាធរសវនកម្មជាតិ

**- ទេសរដ្ឋមន្ត្រី-រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**- អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ខែវិច្ឆិកាឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រមលេខ ០១ នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីប្រពន្ធ័ហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ នឹងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស.រកម/១២៩៩/១៥ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៩

-បានឃើញព្រះរាជក្រមលេខ នស.រកម ១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០២

-បានឃើញអនុក្រឹត្យលេខ៨២អ.ន.ក្រ.ប.កចុះថ្ងៃទី ១៦ខែវិច្ឆិកាឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម.ប្រ.ក. ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុបច្ចុប្បន្ន

## សំរេច

**ប្រការ១ ៈ**-ប្រាក់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌របស់មន្ត្រីរាជការនៃអាជ្ញាធរសវនកម្មជាតិ នឹងត្រូវបើកផ្តល់តាមរយៈ " ភ្នាក់ងារបើកផ្តល់ " ។

**ប្រការ២ៈ**-លោក **ជួន កណ្ណារ៉ា** ត្រូវបានតែងតាំងជាភ្នាក់ងារបើកផ្តល់នៅអាជ្ញាធរសវនកម្មជាតិនិងលោកស្រី **អៀន សារ៉ឹម** ត្រូវបានតែងតាំងជាភ្នាក់ងារបើកផ្តល់ជំនួស ។

**ប្រការ៣ៈ**-លោក **ជួន កណ្ណារ៉ា** និងលោកស្រី **អៀន សារ៉ឹម** ត្រូវបានអនុញ្ញាតឱ្យបើកគណនីប្រាក់បញ្ញើនៅធនាគារជាតិ ដើម្បីទទួលមូលនិធិសំរាប់យកទៅបើកបៀវត្សជូនមន្ត្រីរាជការ និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ ។

**ប្រការ៤ៈ**-បែបបទនៃការអនុវត្តន៍បើកផ្តល់ប្រាក់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ នឹងត្រូវកំណត់ដោយសេចក្តីណែនាំជាក្រោយ ។

**ប្រការ៥ៈ**-ភ្នាក់ងារបើកផ្តល់ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាស និងមូលនិធិដែលបានទទួលដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ ។

**ប្រការ៦ៈ**-អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ប្រធានធនាគារជាតិ ប្រធាននាយកដ្ឋាន ព្រមទាំងប្រធានគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរសវនកម្មជាតិ មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**អគ្គសវនករ**
**នៃអាជ្ញាធរសវនកម្មជាតិ**

**អ៊ុត ឈន**

***កន្លែងទទួល*** :

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*" ដើម្បីជូនជ្រាប "*
*-ដូចប្រការ៦*
*"ដើម្បីអនុវត្ត"*
*-ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
**Ministry of Commerce**
No. [illegible] MoC / M 2002

ភ្នំពេញ. ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០២

# ប្រកាស

## ស្តីពីការរឹបអូសគ្រាក់កក់ពីក្រុមហ៊ុនដែលមិនបាន ទទួលយកកូតាដេញថ្លៃសំរាប់នាំចេញទៅកាន់សហរដ្ឋអាមេរិក ដែលបានដាក់អោយដេញថ្លៃ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០០២

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃ ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសរបស់ក្រសួងពាណិជ្ជកម្ម លេខ ០១៣ MOC/M 2002 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០២ ស្តីពីការដាក់អោយដេញថ្លៃលើកូតាសំលៀកបំពាក់ ដែលត្រូវនាំចេញទៅសហរដ្ឋអាមេរិក សំរាប់ប្រើប្រាស់ក្នុងឆ្នាំ ២០០២
- បានឃើញការចាំបាច់របស់ក្រសួង

## <u>សំរេច</u>

**ប្រការ ១** : រឹបអូសប្រាក់កក់ ចំនួន 10% នៃតម្លៃដេញថ្លៃសរុបរបស់ក្រុមហ៊ុន Cambotex HK Co Ltd លើកូតាប្រភេទ ៦៣៨/៦៣៩ ចំនួន ១០.០០០ ឡូតិ តាមតំលៃ ១.៦០ ដុល្លាសហរដ្ឋអាមេរិក ក្នុងមួយឡូតិ ត្រូវជា ១.៦០០ ដុល្លាសហរដ្ឋអាមេរិក (មួយពាន់ប្រាំមួយរយដុល្លា) ដោយក្រុមហ៊ុននេះ មិនបានបង់ប្រាក់ឱ្យបានទាន់ពេលវេលាតាមកាលកំណត់ ដោយមូលហេតុបោះបង់ចោលកូតាដែលដេញថ្លៃបាន ដូចមានចែងក្នុងប្រការ១១ នៃប្រកាសរបស់ក្រសួងពាណិជ្ជកម្ម លេខ ០១៣ MOC/M 2002 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០២ ស្ដីពីការដាក់អោយដេញថ្លៃកូតាសំលៀកបំពាក់ ដែលត្រូវនាំចេញទៅសហរដ្ឋអាមេរិក សំរាប់ប្រើប្រាស់ ក្នុងឆ្នាំ ២០០២ ។

រីឯបរិមាណកូតាដែលក្រុមហ៊ុនដេញថ្លៃបាននោះ ត្រូវបង្វិលមកក្រសួងពាណិជ្ជកម្មវិញ ដើម្បីទុកសំរាប់ដេញថ្លៃលើកក្រោយទៀត ។

**ប្រការ ២** : ក្រសួងពាណិជ្ជកម្ម រក្សាសិទ្ធិមិនអនុញ្ញាតអោយក្រុមហ៊ុន Cambotex HK Co Ltd ចូលរួមដេញថ្លៃកូតាលើកក្រោយទៀតឡើយ ។

**ប្រការ ៣** : នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស សមាជិកគណកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ ប្រធានក្រុមហ៊ុន Cambotex HK Co Ltd ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម-ប្រសិទ្ធ**

**ចម្លងជូន:**

- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី ស ខេង
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ចការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- ឯកសារ-កាលប្បវត្តិ



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No. ៧៧៣ MoC / M 2002

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០២

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ជំរាបជូន**

- **អ្នកឧកញ៉ាប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ**
- **ប្រធានសមាគមរោងចក្រកាត់ដេរ និងរោងចក្រស្បែកជើងនៅកម្ពុជា**
- **ប្រធានសហព័ន្ធអភិវឌ្ឍន៍កសិកម្មនាំចេញកម្ពុជា**

**កម្មវត្ថុ :** សេចក្តីជូនដំណឹងអំពីការផ្តល់ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម MFN របស់ប្រទេសចិន ដល់ ព្រះរាជាណាចក្រកម្ពុជា ។

សេចក្តីដូចបានជំរាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជូនដំណឹងដល់ អ្នកឧកញ៉ា លោកប្រធានសមាគមទាំងអស់អោយបានជ្រាបថា ដើម្បីពង្រីកការនាំចេញរបស់កម្ពុជា ក្រសួងពាណិជ្ជកម្ម បានខិតខំប្រឹងប្រែងតាមរយៈកិច្ចប្រជុំនានា ទាំងទ្វេរភាគី និងពហុភាគី ដើម្បីស្នើសុំការផ្តល់ភាពអនុគ្រោះផ្នែកពាណិជ្ជកម្មពីប្រទេសចិន ។ នៅថ្ងៃទី២៦ កុម្ភៈ ឆ្នាំ២០០២ ស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិន បានជូនដំណឹងជាផ្លូវការថា រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន បានយល់ព្រមផ្តល់ប្រព័ន្ធអនុគ្រោះ ពាណិជ្ជកម្ម MFN ដល់ប្រទេសកម្ពុជា ក្រោយពីប្រទេសចិនបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ហើយបានចាប់ផ្តើមអនុវត្តច្បាប់ពន្ធនាំចេញនាំចូលថ្មី កាលពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០២ នេះតទៅ ។ នៅក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម MFN នេះ ការនាំចូលទំនិញពីប្រទេសកម្ពុជា នឹងត្រូវបង់ពន្ធតាមអាត្រា MFN ដែលជាអត្រាទាបជាងអត្រាធម្មតាសំរាប់ប្រទេសដែលមិនមែនជា សមាជិកអង្គការ ពាណិជ្ជកម្មពិភពលោក ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមអ្នកឧកញ៉ា លោកប្រធានសមាគមទាំងអស់ជ្រាបជាពត៌មាននិងមានវិធានការដើម្បីអនុវត្តជំរុញការនាំចេញរបស់ខ្លួនឱ្យបានកាន់តែប្រសើរឡើង ។

សូមអ្នកឧកញ៉ា លោកប្រធានសមាគម ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

<u>ចំលងជូន</u>

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានបច្ចេកទេស
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ......៦៦..(២)...ត... ក.អ.ជ

ភ្នំពេញ, ថ្ងៃទី..០៤..ខែ..មេសា......ឆ្នាំ2002..

## ប្រកាស
## ស្តីពីការបង្កើតក្រុមការងារកសាងឯកសារផែនការយុទ្ធសាស្ត្រសំរាប់ការកាត់បន្ថយភាពក្រីក្រ

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រិត្យលេខ នស. កត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រិត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមស្មារតីអង្គប្រជុំ ថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមការងារកសាងឯកសារផែនការជាយុទ្ធសាស្ត្រសំរាប់ការកាត់បន្ថយភាពក្រីក្រ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ និង តំរូវការចាំបាច់។
- យោងតាមតំរូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សំរេច

**ប្រការ១ :** តែងតាំងក្រុមការងារ (រូប) នៃក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានសមាសភាពមន្ត្រីរាជការចំនួន០៧រូប អោយបំពេញការងារបន្ថែមលើមុខងារបច្ចុប្បន្ន ក្នុងការរៀបចំឯកសារផែនការយុទ្ធសាស្ត្រ សំរាប់ការកាត់បន្ថយភាពក្រីក្រ ដែលមានរាយនាមដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម | ប៊ី ធុជ | ប្រធាន |
| ២- | ឯកឧត្តម | បួស គង់ | អនុប្រធាន |
| ៣- | លោក | អ៊ូរ គីមសាន | អនុប្រធាន |
| ៤- | លោក | វ៉ា សំណាង | សមាជិកអចិន្ត្រៃយ៍ |
| ៥- | លោក | ម៉ៅ សារ៉ាយ | សមាជិក |
| ៦- | លោក | វ៉ាន់ សាភឿន | សមាជិក |
| ៧- | លោក | សង ប៊ុនធឿន | លេខាធិការ |

**ប្រការ២ :** ក្រុមការងារ មានភារកិច្ចរៀបចំឯកសារផែនការយុទ្ធសាស្ត្រ សំរាប់ការកាត់បន្ថយភាពក្រីក្រ ដើម្បីចូលរួមក្នុងកម្មវិធីនយោបាយការកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។ ក្រុមការងារនេះមានភារកិច្ចទំនាក់ទំនងផ្ទាល់ និងប្រយោលដល់គ្រប់អង្គភាពក្នុង និងក្រៅក្រសួងក៏ដូចអង្គការជាតិ និងអន្តរជាតិ ដើម្បីប្រមូលទិន្នន័យជាក់លាក់សំរាប់កសាងឯកសារខាងលើ អោយមានប្រសិទ្ធិភាពខ្ពស់ ហើយរាយការណ៍ជូនរាជរដ្ឋាភិបាល។

**ប្រការ៣:** រាល់សេចក្តីប្រកាសណា ដែលផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤:** អគ្គនាយកដ្ឋានទាំងពីរ អគ្គាធិការដ្ឋាន ខុទ្ទកាល័យ គ្រប់នាយកដ្ឋាន មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង និងសាមីខ្លួន មានភារកិច្ចអនុវត្តន៍ តាមប្រកាសនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រី**

លី-ធុជ

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  (ដើម្បីជូនជ្រាប)
- ឯកឧត្តមរដ្ឋលេខាធិការទាំងពីរ
- ឯកឧត្តមអនុរដ្ឋលេខាធិការទាំងប្រាំ
- ដូចប្រការ ៣ ( ដើម្បីអនុវត្តន៍ )
- ឯកសារ-កាលប្បវត្តិ